ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីធ្លី សង្កាត់ស្មាច់មានជ័យ

## ឆ្នាំ ២០០៩-២០២២

## ក្រុង ខេមរភូមិន្ទ ខេត្ត កោះកុង



រៀបចំដោយៈ គណៈកម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំ/សង្កាត់

គាំទ្រដោយៈ ក្រុមសម្របសម្រួលស្រុក និងសម្របសម្រួលផែនការប្រើប្រាស់ដីធ្លីថ្នាក់ស្រុក

ខែ ធ្នូ ឆ្នាំ ២០០៩

# មាតិកា

**អារម្ភកថា** ....... ១

**សេចក្តីផ្តើម** ....... ៣

**ជំពូក ១ ៖ ព័ត៌មាន និងទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់**

១.១ **ស្ថានភាពទូទៅ** ....... ៤

១.១.១ ទីតាំងរដ្ឋបាល ....... ៤

១.១.២ ប្រជាសាស្ត្រ ....... ៥

១.១.៣ ភាពគ្មានដីធ្លី ....... ៦

១.១.៤ ស្ថានភាពសេដ្ឋកិច្ច ....... ៧

១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ ....... ៩

១.១.៦ ស្ថានភាពសុខាភិបាល ....... ១០

១.១.៦.១ ផ្នែកសុខាភិបាល ....... ១០

១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត ....... ១១

**១.២ ស្ថានភាពភូមិសាស្ត្រ** ....... ១២

១.២.១ ទីតាំងភូមិសាស្ត្រ ....... ១២

១.២.២ អាកាសធាតុ ....... ១៣

១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ....... ១៥

**១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** ....... ១៦

១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី ....... ១៦

១.៣.២ ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដី ....... ១៨

១.៣.៣ ផលិតកម្មកសិកម្ម ....... ១៨

១.៣.៤ ធនធានធម្មជាតិ ....... ២១

១.៣.៤.១ ធនធានព្រៃឈើ ....... ២១

១.៣.៤.២ ធនធានជលផលទឹកសាបទឹកប្រៃ ....... ២២

**១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល** ....... ២២

១.៤.១ ទីផ្សារ និង តម្លៃកសិផល ផលអនុផលព្រៃឈើ និងនេសាទ ....... ២២

៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល ....... ២៣

១.៤.៣ ឱកាស ឧបសគ្គ ..... ២៣

## ជំពូក ២ ៖ ការវិភាគពីគំរូការសំរាប់អនាគត ឧបស័គ្គ និងសក្តានុពល

**២.១ តំបន់រសើប** ..... ២៤
២.២ ការប្រឈម/ឧបស័គ្គ ..... ២៤
២.៣ កំណត់គំរូវការនៃការអភិវឌ្ឍន៏ និងគោលដៅយុទ្ធសាស្ត្រសង្កាត់ស្ទឹងវែង ..... ២៥
២.៣.១ គោលដៅនៃការអភិវឌ្ឍន៏ ..... ២៥
២.៣.២ យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៏ ..... ២៥
**២.៤ គំរូវការសំរាប់អនាគត** ..... ២៦
២.៤.១ ប្រជាសាស្ត្រ ..... ២៦
២.៤.១.១ អត្រាកំណើន ..... ២៦
២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ ..... ២៧
២.៤.២ តំរូវការដីសំរាប់លំនៅដ្ឋាន ..... ២៨
២.៤.៣ តំរូវការដីកសិកម្ម ..... ២៨
២.៤.៤ តំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ..... ២៩
២.៤.៥ តំរូវការដីសំរាប់ហេដ្ឋារចនាសម្ពន័សង្គម ..... ២៩
២.៤.៥.១ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៏ និងប្រព័ន្ធស្រោចស្រព ..... ៣០
២.៤.៥.២ តំរូវការសាលារៀន ..... ៣១
២.៣.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត ..... ៣២
២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា ..... ៣៣

## ជំពូក ៣ ៖ ផែនការប្រើប្រាស់ដីអនាគត

**៣.១ ស្ថានភាពដី (សក្តានុពលដី និងតំរូវការដី)** ..... ៣៤
៣.១.១ ស្ថានភាពដីទូទៅ និង សក្តានុពល ..... ៣៤
៣.១.២ តំរូវការដីតាមប្រភេទ ..... ៣៤
**៣.២ ការបែងចែកដីតាមតំរូវការប្រើប្រាស់** ..... ៣៦
៣.២.១ ការវិភាគអន្តរអំពើ ..... ៣៦
៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត ..... ៣៧
៣.២.៣ បរិយាយការប្រើប្រាស់តាមក្បាលដី ..... ៣៧

៣.២.៣.១ ដីលំនៅដ្ឋាន (បញ្ញត្តិគោលការណ៍នៃការប្រើប្រាស់ដី) ...... ៣៨
៣.២.៣.២ ដីស្រែវស្សា និងស្រែប្រាំង ...... ៤០
៣.២.៣.៣ ការប្រើប្រាស់ទឹក និងប្រព័ន្ធស្រោចស្រព ...... ៤០
៣.២.៣.៤ ការសាងសង់ដាក់លូឆ្លងកាត់ផ្លូវ ...... ៤២
៣.២.៣.៥ ការប្រើប្រស់ផ្លូវថ្នល់ ...... ៤២
៣.២.៣.៦ ការប្រើប្រាស់ដីសំរាប់វិស័យសិក្សាធិការ ...... ៤៤
៣.២.៣.៧ ការប្រើប្រាស់ដីក្នុងកិច្ចការពារធនធានធម្មជាតិ និងបរិស្ថាន ...... ៤៦

## ឧបសម្ព័ន្ធ

**ឧបសម្ពន្ធ័ ១ : ការពិពណ៌នាអំពី ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន**
**ឧបសម្ពន្ធ័ ២ : ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន**
**ឧបសម្ពន្ធ័ ៣ : បញ្ហាពាក់ពន្ធ័ក្នុងការប្រើប្រាស់ដី**
**ឧបសម្ពន្ធ័ ៤ : ក្រុបខណ្ឌ័អភិវឌ្ឍន៍**
**ឧបសម្ពន្ធ័ ៥ : បញ្ជីគម្រោង**
**ឧបសម្ពន្ធ័ ៦ : ផែនទីប្រើប្រាស់ដីលំអិត នៅក្នុងសង្កាត់**
**ឧបសម្ពន្ធ័ ៧ : ផែនទីប្រើប្រាស់ដីសាមញ្ញ នៅក្នុងសង្កាត់**
**ឧបសម្ពន្ធ័ ៨ : ផែនទីប្រើប្រាស់ដីនៅពេលអនាគត នៅក្នុងសង្កាត់ឆ្នាំ ២០០៩-២០០២**

# អារម្ភកថា

យើងខ្ញុំទាំងអស់គ្នា ជាសមាជិកក្រុមប្រឹក្សាសង្កាត់ស្មាច់មានជ័យ អាណត្តិទី ២ នេះ មានសេចក្តីសោមនស្សរីករាយក្រៃលែងដែលមានកិត្តិយសបង្ហាញជូននូវផែនការប្រើប្រាស់ដីសំរាប់ការអភិវឌ្ឍន៏សំរាប់ឆ្នាំ ២០០៩-២០២២ ដល់ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលសហការណ៏ក្នុងការអភិវឌ្ឍន៏សង្កាត់យើងខ្ញុំ។ ការចងក្រងឯកសារនេះគឺស្ថិតនៅក្រោមការខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាសង្កាត់ក៏ដូចជាគណកម្មធិការកសាងផែនការ និងថវិកាជាពិសេសមានការចូលរួមពីសំណាក់បងប្អូនប្រជាពលរដ្ឋទាំងមូល និងសហការចូលរួមសំរបសំរួលពីក្រុមរៀបចំផែនការប្រើប្រាស់ដី ក្រុងខេមរភូមិន្ទ ខេត្តកោះកុង (P_LUP) និងគាំទ្របច្ចេកទេសពីក្រុមការងារសមាសភាគរៀបចំដែនដីរបស់អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រោមការឧបត្ថម្ភ ថវិកាពីអង្គការ DANIDA /DFID_Nziad តាមរយៈស្ថានទូតដាណឺម៉ាក់ប្រចាំព្រះរាជាណាចក្រកម្ពុជា។ ផែនការប្រើប្រាស់ដីដែលបានកសាងឡើងនេះពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយចង្អុលបង្ហាញទិសដៅដល់ការអភិវឌ្ឍន៏ របស់សង្កាត់អោយឆ្លើយតបទៅនឹងការបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអោយកាន់តែប្រសើរឡើង។

ក្រុមប្រឹក្សាសង្កាត់ស្មាច់មានជ័យ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អង្គការ DANIDA/DFID/Nziad តាមរយៈស្ថានទូតដាណឺម៉ាក់ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់ថវិកាជំនួយសំរាប់ដំណើរការរៀបចំផែនការប្រើប្រាស់ដីធ្លីនេះ ពីពេលចាប់ផ្តើមរហូតដល់បញ្ចប់ ជាមួយគ្នានោះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារអ្នកសំរបសំរួលថ្នាក់ក្រុងខេមរភូមិន្ទ និងអ្នកសំរបសំរួលថ្នាក់មន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុយោដីខេត្តកោះកុងដែលបានជួយសំរបសំរួលផែនការប្រើប្រាស់ដីអោយទទួលបានភាពជោគ ជ័យ។

ផែនការនេះមិនអាចលេចចេញជារូបរាងបានឡើយ ប្រសិនបើគ្មានការចូលរួមពីសាលាក្រុងខេមរភូមិន្ទការិយាល័យជំនាញនានាជុំវិញក្រុងខេមរភូមិន្ទ និងពីមន្ទីរពាក់ព័ន្ធនានាៗជុំវិញខេត្តកោះកុង។ ដោយឡែកក៏មានការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងៗទៀត ជាពិសេសអង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជនផ្សេងៗទៀតបានរួមចំណែកយ៉ាងថ្លៃថ្លាក្នុងរៀបចំផែនការនេះ។

យើងខ្ញុំទាំងអស់គ្នាជាក្រុមប្រឹក្សាសង្កាត់ និងប្រជាពលរដ្ឋក្នុងសង្កាត់ស្មាច់មានជ័យសង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់នឹងបានយល់ដឹងអំពីស្ថានភាព និងតំរូវការ ព្រមទាំងបញ្ហាប្រឈមទាំងឡាយពាក់ព័ន្ធ និងការប្រើប្រាស់ដីដែលរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៏សង្កាត់ស្មាច់មានជ័យ ហើយនឹងបង្ហាញនូវទឹកចិត្តសប្បុរសធម៌ថ្លៃថ្លា តាមរយៈចូលរួមផ្តល់ជាគំនិត សំភារៈ និងថវិកាសំរាប់គាំទ្រការអភិវឌ្ឍន៏ផែនការប្រើប្រាស់ដី និងដើម្បីចូលរួមចំណែកអភិវឌ្ឍន៏ដោយចិរភាពដល់មូលដ្ឋានសង្កាត់របស់យើងខ្ញុំ។

ជាថ្មីម្តងទៀតតាងនាមឱ្យក្រុមប្រឹក្សាសង្កាត់ និងប្រជាពលរដ្ឋក្នុងសង្កាត់ស្នាច់មានជ័យទាំងមូល សូមសំដែងអំណរគុណយ៉ាងជ្រាលជ្រៅ និងប្រសិទ្ធពរបវរសួស្តីសេរីមង្គល មហាប្រសើរដល់ឯកឧត្តម លោក លោកជំទាវ អស់ លោក លោកស្រី អ្នកនាងកញ្ញាប្រកបតែសេចក្តីសុខគ្រប់ប្រការទទួលបាននូវជ័យជំនះ និងគ្រប់ភារៈកិច្ចកុំបីឃ្លាងឃ្លាតឡើយ។

ធ្វើនៅស្នាច់មានជ័យ. ថ្ងៃទី......... ខែ............ឆ្នាំ ២០០៩

ចៅសង្កាត់

ឆាម_យ៉ុខ

# សេចក្តីផ្តើម

ដោយមានគោលនយោបាយដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ប្រទេសជាតិយើងមានសន្តិភាពសណ្តាប់ធ្នាប់ និងសន្តិសុខល្អ នៅពាសពេញទូទាំងប្រទេសធ្វើអោយសេដ្ឋកិច្ចមានការកើនឡើង ជីវភាពប្រជាជនកើនឡើងគួរឱ្យកត់សំគាល់ ។ ជាក់ស្តែងនាប៉ុន្មានឆ្នាំចុងក្រោយនេះ ទំនិញគ្រប់ប្រភេទមានការកើនឡើងយ៉ាងខ្លាំង ដោយឡែកទីផ្សារដីធ្លីក៏មានការកើនឡើងយ៉ាងគំហុកផងដែរ ។ ចំណែកឯទីផ្សារសង្កាត់ស្ទាច់មានជ័យ ក៏មានការកើនឡើងគួរអោយកត់សំគាល់

ដោយសារមានការកើនឡើងនៃតំលៃដី គួបផ្សំនឹងតំរូវការដីសំរាប់បង្កបង្កើនផលរបស់ប្រជាជនផងនោះទើបនាំអោយមានការកើតឡើងនូវបញ្ហាជាច្រើនដូចជា : ការកាប់ទន្ទ្រានព្រៃឈើ (រួមទាំងព្រៃនៅក្នុងតំបន់ការពារ) ការសាងសង់នៅលើទីតាំងដីមិនសមស្រប ការកាប់ឈើខុសច្បាប់ ការឈូសឆាយការហ៊ុំពទ្ធ័ដីព្រៃឈើការរំលោភយកដីរដ្ឋជាដើម បញ្ហានេះប៉ះពាល់ដល់ការការពារអភិរក្សសត្វព្រៃ ព្រៃឈើធនធានធម្មជាតិ ទេសចរណ៍ធម្មជាតិ ជាពិសេសប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋ និងការរីកចំរើនរបស់ទីក្រុងផងដែរ ។

ការកសាងផែនការប្រើប្រាស់ដី ត្រូវបានចាត់ទុកជាមូលដ្ឋានបច្ចេកទេស និងគតិយុត្តិមួយ សំរាប់ការអភិវឌ្ឍន៏ និងការប្រើប្រាស់ដីសមស្របក្នុងគោលបំណងបំរើផលប្រយោជន៏សាធារណៈ។ ការរៀបចំផែនការមានប្រសិទ្ធភាព គឺជាមធ្យោបាយដ៏ប្រពៃបំផុតដើម្បីឆ្លើយតបទៅនឹងតំរូវការអភិវឌ្ឍន៏ សង្គមកិច្ច-សេដ្ឋកិច្ច និងកិច្ចការពារបរិស្ថាន។ ដូចនេះផែនការនេះគឺជាគន្លឹះមួយដែលរួមចំណែកដល់ការអភិវឌ្ឍន៏ប្រកបដោយចីរភាព របស់រាជរដ្ឋាភិបាលដែលជួយដល់ការអភិវឌ្ឍន៏ចាំបាច់មួយចំនួនទៅលើទីតាំងដ៏សមស្រប និងមិនធ្វើអោយបាត់បង់នូវធនធានធម្មជាតិសំរាប់កូនចៅជំនាន់ក្រោយ។ ដោយមានការព្រួយបារម្ភណ៏អំពីទិសដៅអភិវឌ្ឍន៏មិនមានចីរភាព ដែលអាចបណ្តាលអោយមានការវិនាសដល់ធនធានធម្មជាតិ និងបរិស្ថានកាន់តែខ្លាំង និងបង្កអោយមានផលប៉ះពាល់ដល់ក៏រិតជីវភាពរស់នៅ និងសុខដរមនារបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់ស្ទាច់មានជ័យទាំងមូលនោះ ផែនការនេះនឹងបង្កើតអោយមានក្របខណ្ឌការងារច្បាស់លាស់ក្នុងការរៀបចំផែនការ ប្រើប្រាស់ដី និង ការវិនិយោគទូទៅផងដែរ។

តួយ៉ាងសង្កាត់ស្ទាច់មានជ័យ ជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំងបីរបស់ក្រុមខេមរភូមិន្ទ ដែលសង្កាត់នេះត្រូវបានជ្រើសរើសជាសង្កាត់គោលដៅ សំរាប់អនុវត្តន៏ផែនការប្រើប្រាស់ដីក្នុងគោលបំណងចំបងគឺដើម្បីគាំទ្រដល់ដំណើរការកសាង ផែនការអភិវឌ្ឍន៏សង្កាត់ និងកម្មវិធីវិនិយោគសង្កាត់ សំរាប់ប្រើប្រាស់ក្នុងការរៀបចំអភិវឌ្ឍន៏សង្កាត់ទាំងមូលអោយចំទិសដៅប្រកបដោយនិរន្តភាព និងអោយស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការសំដៅពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល និងដើម្បីលើកស្ទួយសង្គមកិច្ច-សេដ្ឋកិច្ច ជាពិសេសក៏រិត ជីវភាពរស់នៅ និងភាពសុខដុមរមនារបស់ប្រជាពលរដ្ឋអោយកាន់តែប្រសើរឡើង។

# ជំពូក ១

# ព័ត៌មាន និងទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់

## ១.១ ស្ថានភាពទូទៅ

ចាប់តាំងពីក្រោយ ថ្ងៃរំដោះ ០៧ ខែ មករា ឆ្នាំ ១៩៧៩មក សង្កាត់ស្មាច់មានជ័យត្រូវបានផ្លាស់ប្ដូរឈ្មោះជាបន្តបន្ទាប់ដូចខាងក្រោម :

- ពីឆ្នាំ ១៩៧៩ មកដល់ឆ្នាំ ១៩៩៥ មានឈ្មោះថា សង្កាត់ ១ ទីរួមខេត្ត ខេត្តកោះកុង។
- ពីឆ្នាំ ១៩៩៥ មកដល់ឆ្នាំ ២០០៨ ត្រូវបានប្ដូរឈ្មោះមកជា ឃុំស្មាចមានជ័យ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង។
- ពីឆ្នាំ ២០០៨ រហូតមកដល់បច្ចុប្បន្ន ឃុំនេះបានផ្លាស់ប្ដូរឈ្មោះមកជា សង្កាត់ស្មាចមានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

### ១.១.១ ទីតាំងរដ្ឋបាល

| | | |
|---|---|---|
| **ខេត្ត** | កោះកុង | |
| **ក្រុង** | ក្រុងខេមរភូមិន្ទ | |
| **សង្កាត់** | ស្មាច់មានជ័យ | លេខកូដ : ០៩០៤០១ |
| **ចំនួនភូមិ** | ០៥ : ភូមិស្មាច់មានជ័យ ភូមិ១ ភូមិ២ ភូមិ៣ និងភូមិបឹងឃុនឆាង | |

សង្កាត់ស្មាច់មានជ័យជាសង្កាត់ទីរួមខេត្ត ស្ថិតនៅក្នុងក្រុងខេមរភូមិន្ទខេត្តកោះកុង ដែលមានផ្ទៃដីសរុប ៥.៧៤៨,១៩២ហិចតា មានព្រំប្រទល់ខាងជើងទល់នឹងឃុំប៉ាក់ខ្លងស្រុកមណ្ឌលសីមា ខាងត្បូងទល់នឹងសង្កាត់ស្ទឹងវែង និងសង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខាងកើតទល់នឹងឃុំប៉ាក់ខ្លង និងឃុំទួលគគីរស្រុកមណ្ឌលសីមា ខាងលិចទល់នឹងព្រែកកោះប៉ោ ( ព្រំប្រទល់រវាងស្មាច់មានជ័យ និង ឃុំប៉ាក់ខ្លង )ដែលតភ្ជាប់ទៅកាន់ស្រុកមណ្ឌលសីមាដោយស្ពានកោះកុងមានប្រវែង ១៩០០ម ។

ផែនទីបង្ហាញទីតាំង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង




រូបទី ១ : ផែនទីបង្ហាញទីតាំងរដ្ឋបាលសង្កាត់ស្មាច់មានជ័យ

### ១.១.២ ប្រជាសាស្ត្រ

សង្កាត់ស្មាច់មានជ័យមានប្រជាជនសរុបចំនួន ២.០៥២គ្រួសារ ប្រជាជនសរុបចំនួន ១០.៥៥៣ នាក់ ក្នុងនោះស្ត្រី ៥.៥៣៣ នាក់ មានដង់ស៊ីតេ ១៨៤នាក់ ក្នុង១គីឡូម៉ែត្រក្រឡា។ ស្ត្រីជាមេគ្រួសារមាន ចំនួន ១៩៩ គ្រួសារ។ របាយប្រជាជនភាគច្រើនប្រមូលផ្តុំនៅ ប៉ែកខាងលិចត្រង់មាត់ព្រែកកោះប៉ោ រួមមានភូមិចំនួនបួនគឺ ភូមិ១ ភូមិ២ ភូមិ៣ និងភូមិស្មាច់មានជ័យ ដោយឡែកប្រជាជនប្រមាណ១០%ទៀតរស់នៅផ្នែកខាងក្នុងក្បែរព្រលានយន្តហោះ គឺភូមិបឹងឃុនឆាង មកខាងក្នុង (ខាងលិច) ជ្រៅទៀតគឺជាតំបន់ព្រៃមានប្រជាជនរស់តិចតួច។ ប្រជាជនភាគច្រើនជាជនជាតិខ្មែរ តែក៏មានជនជាតិវៀតណាមប្រមាណជា ២% និងជនជាតិឥស្លាមមួយចំនួនតូច(២គ្រួសារ)ដែលជនជាតិវៀតណាមភាគច្រើនប្រកបរបរជាជាងសំណង់ ហើយជនជាតិឥស្លាមគឺមានមុខរបរនេសាទ។ ជាទូទៅប្រជាជនទាំងអស់កាន់ព្រះពុទ្ធសាសនាតែក៏នៅមានជំនឿទៅលើការសែនព្រេនអារក្សអ្នកតាខ្លះៗដែរ ។

**តារាងស្ថិតិប្រជាជនសង្កាត់ស្ទាចមានជ័យ ឆ្នាំ ២០០៨ តាមក្រុមអាយុ**

| ស្ថិតិតាមក្រុមអាយុ | ប្រុស | ស្រី | សរុប | ផ្សេងៗ |
|---|---|---|---|---|
| អាយុក្រោម ០-២ឆ្នាំ | ១៨៦នាក់ | ១៧៥នាក់ | ៣៦១នាក់ | |
| អាយុ ៣-៥ ឆ្នាំ | ៤៦៥នាក់ | ៤៨២នាក់ | ៩៤៧នាក់ | អាយុចូលរៀនមតេយ្យ |
| អាយុពី ៦-១១ឆ្នាំ | ៨៩៩នាក់ | ៩៥០នាក់ | ១៨៤៩នាក់ | អាយុចូលរៀនបឋមសិក្សា |
| អាយុពី ១២-១៤ឆ្នាំ | ៤៤៨នាក់ | ៥៤៦នាក់ | ៩៩៤នាក់ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី ១៥-១៧ឆ្នាំ | ៣៨២នាក់ | ៥០២នាក់ | ៨៨៤នាក់ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ១៨-២៤ឆ្នាំ | ៦២៣នាក់ | ៦១៩នាក់ | ១២៤២នាក់ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី ២៥-៦០ឆ្នាំ | ១៩១៤នាក់ | ២១៥២នាក់ | ៤០៦៦នាក់ | អាយុពេញពលកម្ម |
| អាយុពី ៦១ឆ្នាំឡើងទៅ | ១០៣នាក់ | ១០៧នាក់ | ២១០នាក់ | អាយុចូលនិវត្តន៍ |
| ប្រជាជនសរុប | ៥០២០នាក់ | ៥៥៣៣នាក់ | ១០៥៥៣នាក់ | |
| ចំនួនគ្រួសារសរុប | **២០៥២គ្រួសារ** | | | |

ប្រភពៈសៀវភៅទិន្នភូមិ ឆ្នាំ ២០០៨

### ១.១.៣ ភាពគ្មានដីធ្លី

ក្នុងសង្កាត់ស្ទាច់មានជ័យពិតមែនតែមានដីធំទូលាយតែភាពគ្មានដីធ្លីក៏នៅតែមានជាបញ្ហានៅឡើយសំរាប់ប្រជាជនដែលមានជីវភាពទីទាល់ក្រ ។ ភាពខ្វះខាតដីមាន :

- o គ្រួសារដែលរស់នៅក្នុងបរិវេណតំបន់ការពារអភិរក្សមានចំនួន ៤១ គ្រួសារ
- o គ្រួសារដែលមានផ្ទះរស់នៅលើដីសាធារណៈមានចំនួន ១៣ គ្រួសារ
- o គ្រួសារមានដីស្រែតិចជាង ១ ហ.ត មានចំនួន ២ គ្រួសារ
- o គ្រួសារគ្មានដីធ្វើចំការផ្ទាល់ខ្លួនមានចំនួន២២គ្រួសារ

គ្រួសារដែលរស់នៅលើដីអភិរក្ស លើដីសារធារណៈ គ្រួសារមានដីស្រែតិចជាង ១ ហ.ត និងគ្រួសារគ្មានដីធ្វើចំការពួកគាត់ទាំងអស់នោះភាគច្រើនធ្វើកម្មករ ស៊ីឈ្នួលគេចាំដីអោយគេដើម្បីយកប្រាក់មកផ្គត់ផ្គង់ជីវភាពគ្រួសារបន្ថែម ។

**តារាងចំនួនគ្រួសារដែលគ្មានដី និងគ្រួសារដែលរស់នៅលើដីសាធារណៈ**

| ល.រ | បរិយាយ | ចំនួនគ្រួសារ | ភាគរយប្រជាជន/សរុប | ផ្សេងៗ |
|---|---|---|---|---|
| ១ | គ្រួសាររស់នៅតំបន់ការពារអភិរក្ស | ៤១ | ១.៩៩% | |
| ២ | គ្រួសាររស់នៅលើដីសាធារណៈ | ១៣ | 0.៦៣% | |
| ៣ | គ្រួសារមានដីស្រែតិចជាង ១ ហ.ត | ២ | 0.0៩% | |
| ៤ | គ្រួសារគ្មានដីធ្វើចំការផ្ទាល់ខ្លួន | ២២ | ១.0៧% | |

ប្រភព: ស្ថានភាពឃុំ ឆ្នាំ ២00៩



*រូបថត១ : ផ្ទះនៅលើដីសាធារណៈ*

**១.១.៤. ស្ថានភាពសេដ្ឋកិច្ច**

នៅក្នុងសង្កាត់ស្ទាច់មានជ័យមានប្រជាជនចំនួន១២១គ្រួសារប្រកបរបរកសិកម្មជាចំបង ក្នុងនោះមាន៥គ្រួសារធ្វើស្រែចំបង ដាំដំណាំរួមផ្សំរយៈពេលវែង១៧គ្រួសារ ដាំដំណាំរយៈពេលខ្លី៦៤គ្រួសារ គ្រួសារដាំបន្លែមាន៣៥គ្រួសារ គ្រួសារនេសាទចិញ្ចឹមសត្វ និងយកអនុផលព្រៃឈើមានចំនួន២២0គ្រួសារ គ្រួសារប្រករបរសិប្បកម្មចំបង១៤គ្រួសារ គ្រួសារប្រកបរបរសេវាកម្ម ៩៩៨គ្រួសារ គ្រួសារប្រកបមុខរបរចំរុះក្រៅពីខាងលើមានចំនួន៦៩៩គ្រួសារ ។ គ្រួសារដែលមានសមាជិកធ្វើការនៅក្នុងក្របខណ្ឌរដ្ឋមានចំនួន ៦៧៤ គ្រួសារ គ្រួសារដែលមានសមាជិកជាបុគ្គលិកក្របខណ្ឌឯកជន ១៧៤ គ្រួសារ ។

## តារាងមុខរបរសំខាន់ៗរបស់ប្រជាជនសង្កាត់ស្វាច់មានជ័យ

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | | ផ្សេងៗ |
|---|---|---|---|---|
| | | ចំនួនគ្រួសារ | ភាគរយ (%) | |
| ១ | **មុខរបរកសិកម្ម** | ៣៤១ | ១៦.៦២% | |
| | ធ្វើស្រែចំបង | ០៥ | ០.២៤% | ធ្វើស្រូវចំការ |
| | ដាំដំណាំរយៈពេលវែង | ១៧ | ០.៨៣% | ស្វាយ,ដូង,ខ្នុរ,ធូរេន |
| | ដាំដំណាំរយៈពេលខ្លី | ៦៤ | ៣.១២% | ដំឡូង, ពោត, ចេក |
| | ដាំបន្លែជាចំបង | ៣៥ | ១.៧១% | ត្រកួន,ស្ពៃ,ត្រសក់,ត្រប់ |
| ២ | **នេសាទ ចិញ្ចឹមសត្វ និងអនុផលព្រៃឈើ** | | | |
| | ធ្វើនេសាទចំបង | ១១៣ | ៥.៥១% | លក់ដូរផលនេសាទ |
| | ចិញ្ចឹមសត្វចំបង | ១០៧ | ៥.២១% | គោ,ក្របី,ជ្រូក,មាន់,ទា |
| | អនុផលព្រៃឈើចំបង | 0 | 0% | មាន 0,31% កាលពីឆ្នាំ 2006 |
| ៣ | **គ្រួសារប្រកបមុខរបរសិប្បកម្មចំបង** | ១៤ | ០.៦៨% | |
| | សិប្បកម្មផលិតសង្ហារឹមពីឈើ ផ្តៅ ឬស្សី | ០២ | ០.១០% | តុ,ទូ,កៅអី |
| | សិប្បកម្មផលិតដែកកញ្ចក់អាលុយមីញ៉ូម | ០៤ | ០.១៩% | ធ្វើទ្វារ, បង្អួច |
| | សិប្បកម្មផលិតគ្រឿងបរិភោគ | ០៣ | ០.១៥% | គុទាវ ទឹកសាអុីវ..... |
| | សិប្បកម្មផលិតពោះវៀនកង់ម៉ូតូ | ០៥ | ០.២៤% | គ្រឿងជ័រផ្លាស្ទិក |
| ៤ | **គ្រួសារប្រកបមុខរបរសេវាកម្មជាចំបង** | ៩៩៨ | ៤៨.៦៤% | |
| | ប្រកបមុខរបរជំនួញ | ១១០ | ៥.៣៦% | |
| | ប្រកបមុខរបរជាង | ៣១ | ១.៥១% | |
| | ប្រកបមុខរបរដឹកជញ្ជូន | ៧៤ | ៣.៦១% | |
| | ប្រកបមុខរបរផ្សេងៗ | ៧៨៣ | ៣៨.១៦% | |
| ៥ | **គ្រួសារដែលប្រកបមុខរបរចំរុះក្រៅពីខាងលើ** | ៦៩៩ | ៣៤.០៦% | ដឹកជញ្ជូន ឬជាង |
| | **ស្ថានភាពគ្រួសារមានប្រាក់បៀវត្សរ៍** | | | |
| | គ្រួសារដែលមានសមាជិកធ្វើការនៅក្នុងក្របខណ្ឌរដ្ឋ | ៦៧៤ | ៣២.៨៥% | |
| | គ្រួសារដែលមានសមាជិកជាបុគ្គលិកកម្មករ ក្នុងក្របខណ្ឌឯកជន | ១៧៤ | ៨.៤៨% | |

<u>ប្រភព</u>: ស្ថានភាពឃុំ ឆ្នាំ ២០០៩

### ១.១.៥. ស្ថានភាពអប់រំ និងសិក្សាធិការ

ការអប់រំគឺជាតំរូវការបន្ទាន់ និងចាំបាច់សំរាប់ការអភិវឌ្ឍន៍ធនធានមនុស្សក្នុងសង្កាត់ សំរាប់ការវិនិយោគទៅអនាគត ។ ប៉ុន្តែស្ថានភាពអប់រំក្នុងសង្កាត់នៅមិនទាន់ល្អប្រសើរនៅឡើយ ដោយសារនៅក្នុងសង្កាត់មានសាលាមេត្តេយ្យ មាន ២ សាលា ២បន្ទប់ និង ២ ថ្នាក់ មានចំនួនអ្នកគ្រូ ២ នាក់ សាលាបឋមសិក្សាមានចំនួន ៤ សាលា ស្មើនឹង ៧៧ថ្នាក់ មានគ្រូចំនួន៨៨នាក់ កុមារមិនបានទៅរៀនសរុប៥៥នាក់ ប្រុស២៣នាក់ ស្រី៣២នាក់ដែលមិនបានទៅរៀនសាលាបឋមសិក្សា។ អនុវិទ្យាល័យមាន១សាលា មាន៥បន្ទប់មាន៨ថ្នាក់ ចំនួនគ្រូបង្រៀនមាន២២នាក់ កុមារអាយុ១២-១៤ មិនបានទៅរៀន ៥០ នាក់ ប្រុស២៦នាក់ ស្រី២៤នាក់ ។ ថ្នាក់វិទ្យាល័យមាន១សាលា មាន ២២បន្ទប់ ស្មើ ៤០ ថ្នាក់ គ្រូបង្រៀនមាន ៧៥ នាក់ អាយុពី ១៥-១៧ ឆ្នាំ មានចំនួន៧១នាក់ មិនបានចូលរៀន ប្រុស ២៩ នាក់ ស្រី៤២នាក់ ។

នៅក្នុងសង្កាត់ស្ទាច់មានជ័យ កុមារមិនបានចូលរៀនដោយឪពុកម្តាយមិនយល់ពីតំលៃនៃការសិក្សា និងទុកកូនឱ្យជួយការងារផ្ទះដោយសារជីវភាពខ្វះខាត ដើម្បីឱ្យកុមារបានចូលរៀនគ្រប់ៗគ្នា ក្រុមប្រឹក្សាសង្កាត់មានគំរោងអប់រំទៅដល់ឪពុកម្តាយកុមារឱ្យយល់ពីតំលៃនៃការសិក្សា ដើម្បីអភិវឌ្ឍន៍វិស័យអប់រំនៅក្នុងសង្កាត់ ក្រុមប្រឹក្សាសង្កាត់បានបង្កើតកិច្ចសហការជាមួយមេភូមិ នាយកសាលា គ្រូបង្រៀន និងមាតាបិតាសិស្ស ពិភាក្សារិះរកមធ្យោបាយក្នុងការជំរុញកុមារទាំងអស់ទៅរៀនជាប្រចាំ ឱ្យបានយ៉ាងហោចណាស់ចប់ក៏រិតអនុវិទ្យាល័យដែរ ។

**តារាងស្ថិតិសាលា និងចំនួនសិស្សប្រចាំឆ្នាំ ២០០៨**

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | កុមារសរុប | សិស្សសរុប | សិស្សស្រី | អត្រាមិនចូលរៀន | ភាគរយ |
| ថ្នាក់មត្តេយ្យសិក្សា | ២ | ២ | ២ | ៩៤៧ | ៧៤៣ | ៣៧៥ | ២០៤ | ២២% |
| ថ្នាក់បឋមសិក្សា | ៤ | ៤៣ | ៧៧ | ១៨៤៩ | ១៧៩៤ | ៨៩៥ | ៥៥ | ៣% |
| ថ្នាក់អនុវិទ្យាល័យ | ១ | ៥ | ៨ | ៩៩៤ | ៩៤៤ | ៥១១ | ៥០ | ៥% |
| ថ្នាក់វិទ្យាល័យ | ១ | ២២ | ៤០ | ៨៨៤ | ៨១៣ | ៤៦១ | ៧១ | ៨% |

ប្រភព: ស្ថានភាពឃុំ ឆ្នាំ ២០០៩

**តារាងស្ថិតិចំនួនគ្រូបង្រៀនឆ្នាំ ២០០៩ តាមសៀវភៅទិន្នន័យឃុំ សង្កាត់ ឆ្នាំ ២០០៩**

| ល.រ | ប្រភេទថ្នាក់ | ចំនួនគ្រូបង្រៀន | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រុស | ស្រី | សរុប | |
| ១ | ថ្នាក់មត្តេយ្យសិក្សា | ០ | ០២ | ០២ | |
| ២ | ថ្នាក់បឋមសិក្សា | | | ៨៨ | |
| ៣ | ថ្នាក់អនុវិទ្យាល័យ | | | ២២ | |
| ៤ | ថ្នាក់វិទ្យាល័យ | | | ៧៥ | |

ប្រភព: ស្ថានភាពឃុំ ឆ្នាំ ២០០៩




*រូបថត ២ : សាលារៀន*

## ១.១.៦ ស្ថានភាពសុខាភិបាល

### ១.១.៦.១. ផ្នែកសុខាភិបាល

វិស័យសុខាភិបាលបើនិយាយឱ្យចំទៅ ស្ថានភាពសុខភាពរបស់ប្រជាជនមិនទាន់ចាត់ទុកជាល្អប្រសើរតាមបំណងប្រាថ្នាដែលបានកំណត់ឡើយ នៅក្នុងគោលដៅសហសវត្សរ៍ និងទិសដៅវិស័យសុខាភិបាលប្រសិនបើប្រជាជនមានសុខាភាពល្អ ការប្រកបមុខរបរចិញ្ចឹមជីវិតបានជាប្រក្រតីមិនខាតបង់ពេលវេលា និងទ្រព្យសម្បត្តិទៀតផង ។ ការមានជំងឺ ឬមានសុខាភាពមិនល្អជាកត្តាចំបងនាំឱ្យគ្រួសារមួយចំនួនធ្លាក់ទៅក្នុងភាពក្រីក្រ ការកែលំអសេវាសុខាភាពដែលផ្តល់តាមរយៈមណ្ឌលសុខភាព ការអប់រំប្រជាជននៅក្នុងសង្កាត់ឱ្យយល់ដឹងអំពីសារសំខាន់នៃការនាំកូនមកចាក់ថ្នាំបង្ការការកែប្រែទំលាប់ពីការសំរាលកូនដោយឆ្មបបុរាណ ឱ្យមកប្រើប្រាស់សេវាឆ្មបពេទ្យសម័យ ដែលធានាសុវត្ថិភាពគឺជាការចាំបាច់ដែលត្រូវការគាំទ្រ និងកិច្ចសហការទាំងប្រជាជន ទាំងបុគ្គលិកសុខាភិបាលជំនាញ ។ ក្នុងសង្កាត់ស្មាច់មានជ័យមានមន្ទីរពេទ្យបង្អែកខេត្តមួយកន្លែង ដែលស្ថិតនៅក្នុងភូមិ ១ ។ ចំពោះក្រុមគ្រូពេទ្យនៅមន្ទីរពេទ្យបង្អែកបច្ចុប្បន្នដែលមានក្របខណ្ឌមាន ចំនួនសរុប ៤៨ នាក់ ស្រី ២១ នាក់ ។

### តារាងស្ថិតិមន្ទីរពេទ្យបង្អែកខេត្ត និងចំនួនគ្រូពេទ្យ

| ល.រ | មន្ទីរពេទ្យបង្អែក | សមត្ថភាពផ្គត់ផ្គង់សេវាកម្ម | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ចំនួន | គ្រែ | បន្ទប់ | វេជ្ជបណ្ឌិត | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណ |
| ១ | មន្ទីរពេទ្យបង្អែក | ០១ | ៦៦ | ៦០ | ០៦ | ០៤ | ១២ | |

### ១.១.៦.២. ការផ្គត់ផ្គង់ទឹកស្អាត

ប្រភពនៃការប្រើប្រាស់ទឹកស្អាតខាងលើ ពុំទាន់គ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋសង្កាត់ស្មាច់មានជ័យនៅឡើយព្រោះថាចំពោះអណ្តូងទឹក និង ស្រះទឹកនៅក្នុងសង្កាត់ដែលបានសង់ពីមុខនោះមួយចំនួនត្រូវបានខូច ឬទុក ចោលយូរមិនបានជួសជុលបានទាំងស្រុង ។ ដោយឡែកចំពោះអណ្តូងលូ និងអណ្តូងដៃមួយចំនួនគ្មានទឹក ហើយបើសិន មានទឹកក៏ទឹកនោះមិនអាចប្រើប្រាស់បានឡើយ ដូច្នេះយើងត្រូវស្តារឡើងវិញទាំងស្រុង ។

### តារាងស្ថិតិប្រភពទឹកប្រើប្រាស់ទឹកស្អាតនៅក្នុងសង្កាត់ស្មាច់មានជ័យ

| ល.រ | ប្រភពទឹកស្អាត | ចំនួនប្រភពទឹក | | | សំគាល់ |
|---|---|---|---|---|---|
| | | សរុប | ប្រើបាន | ខូចខាត | |
| ១ | អណ្តូងស្នប់ ឬអណ្តូងជំរុះ | ១២៧ | ៤២ | ៨៥ | ខូចត្រូវជួសជុលឡើងវិញ |
| ២ | អណ្តូងលូ | ៣៣៣ | ២៧៥ | ៥៣ | ខូសត្រូងស្តារឡើងវិញ |
| ៣ | អណ្តូងដៃមិនដាក់លូមិនរៀបឥដ្ឋ | ០១ | ០១ | | |
| ៤ | ចំនួនស្រះទឹកធម្មតា | ១០ | ១០ | ០១ | ស្តារ ឬជួសជុល |

ប្រភព : ស្ថានភាពឃុំ ឆ្នាំ ២០០៩



រូបថត ៣ : អណ្តូងទឹកដៃ

## ១.២ ស្ថានភាពភូមិសាស្ត្រ

### ១.២.១ ទីតាំងភូមិសាស្ត្រ

សង្កាត់ស្ទាច់មានជ័យ គឺជាសង្កាត់មួយដែលស្ថិតនៅតំបន់ជាប់មាត់សមុទ្រ នៅផ្នែកខាងលិច និងតំបន់ជួរភ្នំក្រវាញ នៅផ្នែកខាងកើត ផ្នែកខាងលិចមានលក្ខណៈជាដីទំនាបក្បែរឆ្នេរ ដែលមានរយៈកំពស់ពី 0-៨ម ភាគកណ្តាលមានរយៈកំពស់ខ្ពស់ជាង និងលាយឡំដោយទីទួល មានលក្ខណៈជាទ្រនុងជើងភ្នំ ដែលមានរយៈកំពស់ ៨-៦៥ម ហើយភាគខាងកើតជាតំបន់ភ្នំដែលមានរយៈកំពស់ពី ១០២-៣៥០ម ដោយតំបន់នេះស្ថិតនៅប៉ែកនិរតីជួរភ្នំក្រវាញ តំបន់នេះជាតំបន់ដែលទទួលបានទឹកភ្លៀងយ៉ាងច្រើន ហើយទីជំរាលនៅតំបន់នេះគឺប្រមូលផ្តុំទឹកហូរចាក់ទៅសមុទ្រទាំងអស់ ។ ដីដែលនៅជាប់ដៃសមុទ្រភាគខ្លះជាប្រភេទដីខ្សាច់មិនសូវមានជីវជាតិ និងប្រភេទដីល្បាប់មានជីវជាតិជាតំបន់ព្រៃកោងកាង ។

ផ្នែកខាងត្បូងគឺជាតំបន់មានរយៈកំពស់ 0-៨ម ដែលជាទូទៅតំបន់នេះគឺជាតំបន់ព្រៃស្តើង ហើយងាយស្រួលប្រឈម នឹងការហូរច្រោះ ។ ផ្នែកខាងជើងមានគឺជាតំបន់មានរយៈកំពស់ពី 0-៨ម ដែលជាតំបន់ដីស្តើង ហើយងាយស្រួលប្រឈមនឹងការហូរ ច្រោះដីដូចតំបន់ខាងត្បូងផងដែរ ។




រូបទី ២ : ផែនទីរយៈកំពស់ក្នុងសង្កាត់ស្ទាច់មានជ័យ

### ១.២.២. អាកាសធាតុ

នៅក្នុងខេត្តកោះកុងយើងសង្កេតឃើញថាមានរដូវពីរផ្សេងគ្នាគឺរដូវប្រាំង និងរដូវវស្សា ដែលរដូវប្រាំង មានចំនួន ០៥ ខែគឺចាប់ពីខែ ធ្នូ រហូតដល់ខែ មេសា ប៉ុន្តែក៏មានការប្រែប្រួលដោយជួនកាលមានរាំងភ្លៀងនៅពាក់កណ្តាលខែវិច្ឆិកាផងដែរ។ ដោយឡែកខេត្តកោះកុងគឺជាខេត្តមួយដែលមានធ្លាក់ច្រើនជាងគេ ព្រោះវាជាខេត្តដែលនៅជាប់នឹងសមុទ្រ ហើយហ៊ុំព័ទ្ធទៅដោយប្រជុំភ្នំ (ជួរភ្នំក្រវ៉ាញ) ដែលវាជារនាំងបាំងចំហាយទឹកភ្លៀង និងខ្យល់មួយភាគធំ។ ដូច្នេះកត្តាទាំងនេះដែលជាហេតុធ្វើអោយអំណោយផលយ៉ាងខ្លះចំពោះខេត្តកោះកុង។ នៅក្នុងរយៈពេលពីឆ្នាំ ១៩៩៩-២០០៨ យើងសង្កេតឃើញថាបរិមាណទឹកភ្លៀងធ្លាក់ច្រើនជាងគេ គឺក្នុងកំឡុងឆ្នាំ ២០០៧ ដែលមានប្រមាណ ៨៩.៨៦០ មម ជាពិសេសក្នុងខែកក្កដា។

**តារាងកំពស់ទឹកភ្លៀង**

| ស្ថានភាព | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១៩៩៩ | 0 | ១.៤៣៨ | ១.៦០១ | ៤.៦១៧ | ៦.៨៤២ | ២.២២៦ | ៩.០១៦ | ៤.១០៥ | ២.៩៤៦ | ១.៨៣៣ | 0 | 0 |
| ២000 | ១.១៧៣ | ៧៨៥ | ៧៤២ | ១៤៨ | ៧.៨០៩ | ៤.៥០៧ | ១០.៤៨១ | ១៥.៣១៦ | ២០៣ | ៤.២៨៩ | ៤៣ | ៩៥៦ |
| ២00១ | ១.២១៩ | ៨.0៨0 | ១.៥៩៧ | ២.២៤៤ | ១១.៥៧៥ | ៥.៨៤៤ | ៧.១២១ | ៩.៣១៦ | ៤.២៧១ | ៣.៥៦៩ | ២៦ | ៩១ |
| ២00២ | 0 | 0 | ៨៦៣ | ១៧២ | ៧.៨២៤ | ៣.៦៩៣ | ៥.០៤៣ | ៨.៨៦២ | ៦.០៤៤ | ៧៧ | ៧៩៥ | ៣៨២ |
| ២00៣ | 0 | ៣៧៧ | ៣៨៧ | ៩១៣ | ២.៩១៤ | ២.៥១៣ | ៩.២៩៤ | ៥.៩៣៨ | ៤.៩៣៩ | ៣.៧២៤ | ៥ | 0 |
| ២00៤ | ៤៧៤ | ៩៤៤ | ៥៤៨ | ៣៧២ | ៦៩៤ | ១.៨២៩ | ៨.៧២១ | ១០.៥២២ | ២៤២ | ២.៤៥៧ | ៦០៥ | 0 |
| ២00៥ | 0 | 0 | 0 | ១.៣៣២ | ៧.២៧៧ | ៣.៣៧៦ | ១០.៤០៨ | ៤៦៦ | ៦.២៧៤ | ២.២២៦ | 0 | 0 |
| ២00៦ | ៤៨៧ | ១.៤៧៧ | ៦៤៩ | ១.០៥៥ | ៤.១៣៧ | ៥.៩២៦ | ១៧.១៧៤ | ៨.៦៩២ | ៥.៨៤២ | ៥.២៨៥ | ១២៣ | ៦២ |
| ២00៧ | ៦៦ | ៣២ | ៤៧៨ | ២.៥៩៦ | ៤.២៨៨ | ៣.១៩១ | ៨៩.៨៦0 | ៧.៤៦៨ | ៧.៥៧៣ | ២.៦៥៩ | ៤៧៥ | ១៩១ |
| ២00៨ | ២៨ | ៤៧៧ | ១.០៨៥ | ៣.៤៧៧ | ៥.៥៨២ | ៦.៣៨៨ | ៧.០១២ | ៧.៦០៧ | ៦.៥១២ | ២.៧៣៩ | ៦0 | ៣៨៥ |

*ប្រភព : នាយកដ្ឋានឧតុនិយម និងជលសាស្ត្រ*




*ក្រាហ្វិក : កំពស់ទឹកភ្លៀងប្រចាំឆ្នាំ/ខែ*

### ១.២.៣. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន :

ផ្លូវគោកមានសកម្មភាពជាចំបងរបស់សង្កាត់ស្ទាច់មានជ័យ មានហេដ្ឋារចនាសម្ព័ន្ធ និងមានផ្លូវលំកាត់ខ្វាត់ខ្វែងគ្រប់ភូមិយ៉ាងច្រើនចំងាយមធ្យមពីភូមិទៅផ្សារដែលនៅជិតបំផុតមានចំងាយ ១,៩៦ គម. និងចំងាយពីភូមិទៅសាលាសង្កាត់ ១,៧ គម. ទោះបីចំងាយនេះមិនជាឆ្ងាយ ប៉ុន្តែការធ្វើដំណើរជួបប្រទះការលំបាក។ មធ្យោបាយដឹកជញ្ជូនតាមកង់ ម៉ូតូ រឺម៉ក ឬរថយន្តផ្សេងៗ ចំពោះរថយន្តដឹកអ្នកដំណើរបំរើសកម្មភាពផ្នែកសេវាកម្មដឹកជញ្ជូន គ្រាន់តែជាមុខរបរបន្ទាប់បន្សំ ដូចជាសកម្មភាពដឹកអ្នកដំណើរ និងទំនិញបន្តិចបន្តួចតែប៉ុណ្ណោះរបស់ប្រជាជននៅក្នុងសង្កាត់ ដែលទិន្នន័យបង្ហាញថាគ្រួសារប្រកបរបរដឹកជញ្ជូនមានចំនួនតិច ។

សង្កាត់ស្ទាច់មានជ័យមានហេដ្ឋារចនាសម្ព័ន្ធផ្លូវច្រើនយ៉ាង ដូចជាផ្លូវកៅស៊ូ ផ្លូវបេតុង ផ្លូវគ្រួសក្រហម ផ្លូវដីស និងផ្លូវធម្មតា ។

## តារាងស្ថិតិផ្លូវក្នុងសង្កាត់ស្ទាច់មានជ័យ

| ល.រ | បរិយាយ | ចំនួនខ្សែ | ប្រវែង | ផ្សេងៗ |
|---|---|---|---|---|
| ១ | ប្រភេទផ្លូវកៅស៊ូ | ០៨ | ១៥.២៦៣ ម | |
| ២ | ផ្លូវបេតុង | ០៤ | ១.៩៥០ ម | |
| ៣ | ផ្លូវគ្រួសក្រហម | ៣៥ | ៥០.៩៧៩ ម | |
| ៤ | ផ្លូវដីស/ផ្លូវថ្មើរជើង | ០៣ | ៤១.២៩៦ ម | |
| ៥ | ផ្លូវក្នុងខេត្ត | | ១៧.៦៣៧ ម | |
| | ស្ពាន | | ៩៥០ | |

*ប្រភព : ទិន្នន័យព័ត៌មានភូមិសាស្ត្របានពីការធ្វើបច្ចុប្បន្នភាព*



*រូបថត ៤ : ផ្លូវកៅស៊ូ*

## ១.៣. ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១. ស្ថានភាពនៃការប្រើប្រាស់ដី

ការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្ទាច់មានជ័យ ចែកចេញជា ៣១ ចំណាត់ថ្នាក់រួមមាន :

## តារាងប្រភេទនៃការប្រើប្រាស់ដីលំអិត

| ល.រ | ប្រភេទនៃការប្រើប្រាស់ដី | ទំហំ( (ហត) | | ចំណាត់ថ្នាក់របស់មូលដ្ឋាន |
|---|---|---|---|---|
| | | គម$^{២}$ | ហត | |
| ដីមានផលិតភាពទាប | | | | |
| ១ | ដីលំនៅដ្ឋានប្រជុំជន | ២.៨៧ | ២៨៦.៦០ | ផ្ទះពុំមានដីសំរាប់ដាំដំណាំ លក់ដូរទំនិញ |
| ២ | ដីលំនៅដ្ឋានភូមិ | ១.១៥ | ១១៤.៥០ | ផ្ទះដំណាំឈើហូបផ្លែ |
| ៣ | ដីហេដ្ឋារចនាសម្ព័ន្ធ | ០.៧៧ | ៧៦.៧០ | សំណង់អាគាររដ្ឋ, មន្ទីរពេទ្យ, សួនច្បារ, វត្ត |
| ៤ | ដីអាកាសយាន្តដ្ឋាន | ០.៥៦ | ៥៥.៣០ | ព្រលានយន្តហោះ |
| ៥ | ដីកប់ខ្មោច | ០.០២ | ១.០៩ | បញ្ចុះសព |
| ៦ | ដីចំការឈើហូបផ្លែ | ៣.៧៤ | ៣៧៣.៨០ | ចំការឈើហូបផ្លែរយៈពេលយូរ |
| ៧ | ដីចំការឈើហូបផ្លែ និងដីភូមិចាស់ | ០.០៤ | ៣.៥០ | ដីលែងមានការសាងសង់លំនៅដ្ឋាន សល់តែដំណាំ |
| ៨ | ដីចំការកៅស៊ូ | ១.៩៣ | ១៩២.៧៧ | ដីដាំឈើកៅស៊ូ |
| ៩ | ចំការព្រៃដាំ | ២.១៧ | ២១៦.៤២ | ដីដាំដើមខ្លឹមច័ន្ទ ឬឈើលោក |
| ១០ | ព្រៃស្រោង | ១៨.១១ | ១៨១០.៧២ | ព្រៃក្រាស់ដើមឈើធំខ្ពស់ៗ និងព្រៃតូចៗដុះលាយ ជាមួយ |
| ១១ | ព្រៃរបោះ | ៣.៩១ | ២៥.៦១ | ព្រៃមានតែដើមឈើធំខ្ពស់ៗ ពុំមានព្រៃតូចៗ |
| ១២ | ព្រៃរបោះស្តើងស្ងួត | ០.១៩ | ១៨.៩៨ | ព្រៃមានតែដើមឈើធំខ្ពស់ៗ មិនសូវញឹក និងពុំមាន ព្រៃតូចៗ |
| ១៣ | ព្រៃដុះតាមមាត់ទឹក | ០.៣៣ | ៣២.១៥ | ដើមស្នាច់, ក្រញូង, ស្នៃ កោងកាង និងដើមចាក |
| ១៤ | ព្រៃដុះឡើងវិញ | ១.៧៧ | ១៧៦.៧៣ | ដើមត្រសេក ដើមក្រខុបព្រៃ |
| ១៥ | ព្រៃឬស្សី | ០.០២ | ១.៧២ | ឬស្សីចំណីដំរី |
| ១៦ | ព្រៃកោងកាង | ០.៦៩ | ៦៨.៧៣ | ព្រៃលិចទឹកដុះតាមមាត់សមុទ្រ |
| ១៧ | ព្រៃកោងកាងស្តើង | ០.៣៣ | ៣២.៤៥ | ព្រៃលិចទឹកដុះតាមមាត់សមុទ្រ |
| ១៨ | ល្បាយដីព្រៃលាយដីចំការ | ៤.០១ | ៤០០.៧៧ | ដីចំការបុស ឬស្រូវចំការ |
| ១៩ | វាលស្មៅ | ៦.៧៧ | ៦៧៦.៤៦ | វាលស្មៅ |
| ២០ | វាលស្មៅលិចទឹក | ០.០៧ | ៦.៦៥ | ស្មៅលិចទឹក |

| | | | | |
|---|---|---|---|---|
| ២១ | ព្រៃគម្ពោត | 0.0២ | ១.៦២ | ព្រៃគម្ពោត |
| ២២ | ព្រៃគម្ពោតលាយដើមឈើធំមួយៗ | 0.0៣ | ២.៨៩ | ព្រៃរិចរិល |
| ២៣ | បឹង | 0.0៧ | ៦.៦៩ | បឹង |
| ២៤ | បឹងមានទឹកនៅរដូវវស្សា | 0.0២ | ១.៩៣ | បឹង |
| ២៥ | ស្រះ | 0.0៤ | ៣.៥៨ | ស្រះ |
| ២៦ | ស្ទឹង | 0.0៧ | ៦.២៧ | ព្រែក ឃ្លង |
| ២៧ | សមុទ្រ | ៣.២៨ | ៣២៧.៦៩ | សមុទ្រ |
| ២៨ | ស្រែចិញ្ចឹមបង្គា | 0.១២ | ១១.៨២ | ស្រែបង្គា |
| ២៩ | ដីដែលគ្មានរុក្ខជាតិដុះគ្របដណ្តប់ | 0.0៤ | ៤.0៨ | ដីវាលខ្សាច់ ផ្ទាំងថ្ម |
| ៣0 | តំបន់រយរ៉ែ | 0.0៦ | ៥.៤៨ | ការយកដីក្រហម និងថ្មភ្នំ |
| ៣១ | ព្រៃកាប់ឆ្ការ | ១.៤៣ | ១៤២.២៤ | ដីកាប់ព្រៃធ្វើចំការ |
| | **ផ្ទៃសរុប** | | **៥0៨៥.៩៤** | |

<u>ប្រភព</u> : លំអិតអំពីប្រភេទនៃការប្រើប្រាស់ដីនីមួយៗ មានពិពណ៌នាលំអិតនៅក្នុងឧបសម្ព័ន្ធ ១ និង មានភ្ជាប់ជាមួយនូវផែនទីប្រើប្រាស់ដីលំអិត និងសាមញ្ញខ្នាត A3)

### ១.៣.២. ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដី

ស្ថានភាពនៃការគ្រប់គ្រងដីនៅក្នុងសង្កាត់ស្ទាច់មានជ័យ គឺបានចុះបញ្ជី និងធ្វើការចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋបានចំនួន ១៣៤៦.៥៧៦៥ ហិកតា តែបច្ចុប្បន្នដោយសារការកើនឡើងរបស់ប្រជាជននៅក្នុងសង្កាត់មានការហូរចូលដោយសារអ្នកនោះមកតាំងទីលំនៅថ្មី មានការទិញលក់ដីក៏កើនឡើងដែរ ប៉ុន្តែពុំមានរូបភាពណាមួយធំទេ ។

**តារាងសកម្មភាពនៃការកាន់កាប់ និងគ្រប់គ្រងដី**

| ល.រ | ប្រភេទនៃការគ្រប់គ្រង | ទំហំដី (ហ.ត) | ផ្សេងៗ |
|---|---|---|---|
| ១ | ក្រុមហ៊ុនព្រៃសម្បទានហ្គោត | ២.៧៧៥.២២ | បច្ចុប្បន្នក្រុមហ៊ុននេះបញ្ចប់កិច្ចសន្យាជាមួយរដ្ឋាភិបាលរួចហើយ |

### ១.៣.៣. ផលិតកម្មកសិកម្ម

ប្រជាជនច្រើនធ្វើស្រូវចំការតាមទំលាប់ ពុំមានប្រព័ន្ធធារាសាស្ត្រផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ឡើយ គឺកសិកម្មដែលពឹងផ្អែកទៅលើទឹកភ្លៀងទាំងស្រុង ប្រជាកសិករក៏គ្មានដីស្រែធ្វើច្រើនឡើយ ដោយពួកគាត់ជួលដីស្រែគេបង្កបង្កើនផល តាមលក្ខណៈធម្មជាតិ ការបង្កបង្កើនផលមានតែមួយដងក្នុងមួយឆ្នាំ ប្រើតែពូជក្នុងស្រុក ចំពោះការយល់ដឹងបច្ចេកទេសដាំដុះរបស់ប្រជាជននៅមានកំរិតទាប ពុំមានការប្រើប្រាស់ជីគីមី ឬថ្នាំសំលាប់សត្វល្អិតក៏គាត់មិនបានប្រើដែរ ។

តំបន់វាលរាបដែលជាតំបន់ការងារដាំដុះ ភាគច្រើនជាប្រភេទដីខ្សោះជីវជាតិ ដូចជានៅភូមិបឹងឃុនឆាង ភូមិស្នាច់មានជ័យ និងភូមិ ៣ ។ ជារួមលើវិស័យដាំដុះក្នុងសង្កាត់ ការពង្រីកផ្ទៃដីកសិកម្មអាចនឹងធ្វើទៅបានក្នុងលក្ខណៈស្តួចស្តើង ។

ប្រជាជនភាគច្រើននៅក្នុងសង្កាត់មានមុខរបរចិញ្ចឹមសត្វ ក្នុងនោះគ្រួសារចិញ្ចឹមគោ-ក្របីសរុប ៤៥ គ្រួសារ គ្រួសារចិញ្ចឹមជ្រូកសរុប ១២៥ គ្រួសារ គ្រួសារចិញ្ចឹមមាន់សរុប ៧៤៨ គ្រួសារ គ្រួសារចិញ្ចឹមទាមានចំនួន ៤៩ គ្រួសារ ។ ប្រជាជនក្នុងសង្កាត់និយមការចិញ្ចឹម ប៉ុន្តែការចិញ្ចឹមសត្វរបស់ប្រជាជនមានតែលក្ខណៈគ្រួសារ មិនទាន់មានទ្រង់ទ្រាយធំនៅឡើយ ដោយសារតែប្រជាជនខ្វះបច្ចេកទេសក្នុងការចិញ្ចឹម ចំពោះដំណាំរួមផ្សំសង្កាត់មានដីចំការសរុប ៤៥ ហិកតា នៅក្នុងសង្កាត់មិនមានចំការជាទ្រង់ទ្រាយធំទេ គឺជាលក្ខណៈគ្រួសារ ដូចជាចំការត្រសក់ ស្ពៃ ត្រកួន បន្តិចបន្តួចសំរាប់ដោះស្រាយជីវភាពតាមគ្រួសារតែប៉ុណ្ណោះ ជាទិសដៅដោយសារសក្តានុពលដីនៅក្នុងភូមិបឹងឃុនឆាង ភូមិស្នាច់មានជ័យ និង ភូមិ ៣ អាចឱ្យប្រជាជនដាំដំណាំរួមផ្សំផ្សេងៗបន្ថែមទៀត ក្រៅពីធ្វើស្រែចំការ ដើម្បីជួយសំរួលដោះស្រាយជីវភាពតាមគ្រួសារ ។

**តារាង ក្រឡាផ្ទៃតាមផលិតភាពដី និងការប្រើប្រាស់ និងផលិតផល**

| ល.រ | ប្រភេទនៃការប្រើប្រាស់ដី | ទំហំ (ហត) | | ចំណាត់ថ្នាក់របស់មូលដ្ឋាន |
|---|---|---|---|---|
| | | គម² | ហត | |
| ដីមានផលិតភាពទាប | | | | |
| ១ | ដីលំនៅដ្ឋានប្រជុំជន | ២.៨៧ | ២៨៦.៦០ | ផ្ទះពុំមានដីសំរាប់ដាំដំណាំ លក់ដូរទំនិញ |
| ២ | ដីលំនៅដ្ឋាន | ១.១៥ | ១១៤.៥០ | ផ្ទះដំណាំឈើហូបផ្លែ |
| ៣ | ដីហេដ្ឋារចនាសម្ព័ន្ធ | ០.៧៧ | ៧៦.៧០ | សំណង់អាគាររដ្ឋ, មន្ទីរពេទ្យ, សួនច្បារ, វត្ត |
| ៤ | ដីអាកាសយានដ្ឋាន | ០.៥៦ | ៥៥.៣០ | ព្រលានយន្តហោះ |
| ៥ | ដីកប់ខ្មោច | ០.០២ | ១.០៩ | បញ្ចុះសព |
| ៦ | ដីចំការឈើហូបផ្លែ | ៣.៧៤ | ៣៧៣.៨០ | ចំការឈើហូបផ្លែរយៈពេលយូរ |
| ៧ | ដីចំការឈើហូបផ្លែ និងដីភូមិចាស់ | ០.០៤ | ៣.៥០ | ដីលែងមានការសាងសង់លំនៅដ្ឋាន សល់តែដំណាំ |
| ៨ | ដីចំការកៅស៊ូ | ១.៩៣ | ១៩២.៧៧ | ដីដាំឈើកៅស៊ូ |
| ៩ | ចំការព្រៃដាំ | ២.១៧ | ២១៦.៤២ | ដីដាំដើមខ្លឹមច័ន្ទ ឬឈើលោក |
| ១០ | ព្រៃស្រោង | ១៨.១១ | ១៨១០.៧២ | ព្រៃក្រាស់ដើមឈើធំខ្ពស់ៗ និងព្រៃតូចៗដុះលាយ ជាមួយ |

| | | | | |
|---|---|---|---|---|
| ១១ | ព្រៃរបោះ | ៣.៩១ | ២៥.៦១ | ព្រៃព្រាមតែដើមឈើធំខ្ពស់ៗ ពុំមានព្រៃតូចៗ |
| ១២ | ព្រៃរបោះស្តើងស្ងួត | ០.១៩ | ១៨.៩៨ | ព្រៃព្រាមតែដើមឈើធំខ្ពស់ៗ មិនសូវញឹក និងពុំមាន ព្រៃតូចៗ |
| ១៣ | ព្រៃដុះតាមមាត់ទឹក | ០.៣៣ | ៣២.១៥ | ដើមស្ទាច់, ក្រញូប, ស្មែ កោងកាង និងដើមចាក |
| ១៤ | ព្រៃដុះឡើងវិញ | ១.៧៧ | ១៧៦.៧៣ | ដើមត្រសេក ដើមក្រខុបព្រៃ |
| ១៥ | ព្រៃឫស្សី | ០.០២ | ១.៧២ | ឫស្សីចំណីដីរ |
| ១៦ | ព្រៃកោងកាង | ០.៦៩ | ៦៨.៧៣ | ព្រៃលិចទឹកដុះតាមមាត់សមុទ្រ |
| ១៧ | ព្រៃកោងកាងស្តើង | ០.៣៣ | ៣២.៤៥ | ព្រៃលិចទឹកដុះតាមមាត់សមុទ្រ |
| ១៨ | ល្បាយដីព្រៃលាយដីចំការ | ៤.០១ | ៤០០.៧៧ | ដីចំការបុស ឬស្រូវចំការ |
| ១៩ | វាលស្មៅ | ៦.៧៧ | ៦៧៦.៤៦ | វាលស្មៅ |
| ២០ | វាលស្មៅលិចទឹក | ០.០៧ | ៦.៦៥ | ស្មៅលិចទឹក |
| ២១ | ព្រៃគម្ពោត | ០.០២ | ១.៦២ | ព្រៃគម្ពោត |
| ២២ | ព្រៃគម្ពោតលាយដើមឈើធំមួយៗ | ០.០៣ | ២.៨៩ | ព្រៃរិចរិល |
| ២៣ | បឹង | ០.០៧ | ៦.៦៩ | បឹង |
| ២៤ | បឹងមានទឹកនៅរដូវវស្សា | ០.០២ | ១.៩៣ | បឹង |
| ២៥ | ស្រះ | ០.០៤ | ៣.៥៨ | ស្រះ |
| ២៦ | ស្ទឹង | ០.០៧ | ៦.២៧ | ព្រែក ឃ្លង |
| ២៧ | សមុទ្រ | ៣.២៨ | ៣២៧.៦៩ | សមុទ្រ |
| ២៨ | ស្រែចិញ្ចឹមបង្គា | ០.១២ | ១១.៨២ | ស្រែបង្គា |
| ២៩ | ដីដែលគ្មានរុក្ខជាតិដុះគ្របដណ្តប់ | ០.០៤ | ៤.០៨ | ដីវាលខ្សាច់ ផ្ទាំងថ្ម |
| ៣០ | តំបន់យករ៉ែ | ០.០៦ | ៥.៤៨ | ការយកដីក្រហម និងថ្មភ្នំ |
| ៣១ | ព្រៃកាប់ឆ្ការ | ១.៤៣ | ១៤២.២៤ | ដីកាប់ព្រៃធ្វើចំការ |

ប្រភព: ទិន្នន័យ GIS

ផែនទីផលិតភាពដី ក្នុងសង្កាត់ស្មាច់មានជ័យ




**រូបទី ៣ : ផែនទីបង្ហាញពីផលិតភាពដី**

### ១.៣.៤. ធនធានធម្មជាតិ

សង្កាត់ស្មាច់មានជ័យជាស្កាត់មួយក្នុងចំណោមសង្កាត់ទាំង ៣ ដែលសំបូរទៅដោយធនធានធម្មជាតិ តំបន់នេះមានប្រវត្តិជាខេត្តមួយដាច់ស្រយាល មានមនុស្សមករស់នៅតិចតួច ហើយពីអតីតកាលផ្លូវគមនាគមន៏មកកាន់ខេត្តកោះកុងនេះមានការលំបាក ហេតុនេះហើយមិនសូវមានសម្ពាធទៅលើធនធានធម្មជាតិឡើយ ពិសេសតំបន់ដែលស្ថិតនៅឆ្ងាយពីមាត់សមុទ្រ និងឆ្ងាយពីទីប្រជុំជន ។

#### ១.៣.៤.១. ធនធានព្រៃឈើ

សង្កាត់ស្មាច់មានជ័យជាសង្កាត់សំបូរទៅដោយធនធានព្រៃឈើដែលរួមមានៈ ព្រៃកោងកាងកាញ្ចឹប ស្មែរ ដុះនៅតាមមាត់ឆ្នេរសមុទ្រ ឬដៃសមុទ្រ ព្រៃស្មាច់ដុះនៅតាមតំបន់ទំនាបលាយឡំនឹងព្រៃល្បោះ ព្រៃស្រោងក្រាស់ដែលដុះភ្ជាប់ទៅនឹងតំបន់ជួរភ្នំក្រវាញ ដែលសំបូរទៅដោយប្រភេទឈើមានតំលៃសេដ្ឋកិច្ច គឺប្រភេទឈើដែលជាលក្ខណៈពិសេសក្នុង តំបន់ គឺដើមគគីរធំ គគីរខ្សាច់ ដើមផ្ចឿក ដើមកំញ្ចាណ ដើមឈើទាល ដើមបាយពូវាំង ហើយដើមដែលគេស្គាល់ស្ទើរគ្រប់គ្នានោះគឺដើមខ្លឹមចាន់គ្រឹះស្នា ដែលគេនិយមហៅថាដើមឈើលោក ព្រៃឈើទាំងនេះដែលស្ថិតក្នុងតំបន់អភិរក្សជួរភ្នំក្រវ៉ាញ (Wild Aid) និងរដ្ឋបាលព្រៃឈើ ។

- **អនុផលព្រៃឈើ**

មានផ្តៅ ឬស្សី វល្លិ៍រមៀត វល្លិ៍អន្ទុង សូតដីរ ផ្លែគុយ ផ្លែម៉ាក់ប្រាំង ជ័ររុង និងដើមកូនស្លាព្រៃ អុសធ្យូង

- **ប្រភេទសត្វព្រៃ**

មានទន្សោង មាន់ព្រៃ ជ្រូកព្រៃ ឈ្លូស ប្រើស ខ្លាឃ្មុំ ខ្លារខិន ខ្លាដំបង ខ្លាត្រី រញ្ជី ពង្រួល កំប្រុក អន្សង ត្រកួត ទោច ស្វា ពស់ និង អណ្តើក ។

**១.៣.៤.២. ធនធានជលផលទឹកសាប និងទឹកប្រៃ**

ក- មានត្រីរស់ ក្រាញ់ កំភ្លៀញ កន្ធរ អណ្តែង ផ្ទក អន្ទង់ ក្តាម ខ្យង និង ខ្សៅ ។

ខ- មានត្រីក្រម៉ុង ត្រីឆ្លង់ស ត្រីឆ្លង់ក្រហម ត្រីក្បក ត្រីបបែល ត្រីអណ្តែងប៉ុយ ត្រីកណ្តាំង ត្រីផ្ទង ត្រីអណ្តាតឆ្កែ មឹក ត្រីកន្ទុយរឹង ត្រីក្តចិន ត្រីឆ្លាម ត្រីដាវ ត្រីបេកា ត្រីអង្រៃ បងា ក្តាមថ្ម ក្តាមផ្តលាន់ ក្តាមជ័រ ក្តាមសេះ និងអណ្តើកសមុទ្រ ។

## ១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល :

### ១.៤.១. ទីផ្សារ និងតំលៃកសិផល ផល និងអនុផលព្រៃឈើ និងផលនេសាទ

**ផ្នែកអនុផលព្រៃឈើ :**

| | | | |
|---|---|---|---|
| - ផលអនុផលផ្តៅ | ១ ដើម | មានតំលៃ | ១.០០០៛ |
| - ឬស្សី | ១ បាច់ | មានតំលៃ | ១០.០០០៛ |
| - សូតដីរ | ១ គ.ក្រ | មានតំលៃ | ១.៥០០៛ |
| - កូនស្លាព្រៃ | ១ ដើម | មានតំលៃ | ១.០០០៛ |
| - អុស | ១ បាច់ធំ | មានតំលៃ | ២.៥០០-៣.០០០៛ |
| - ធ្យូង | ១ បាវស៊ីម៉ង់ត៍ | មានតំលៃ | ១០.០០០-១២.០០០៛ |

**ផ្នែកផលនេសាទត្រីទឹកប្រៃ :**

| | | | |
|---|---|---|---|
| - ត្រីក្រម៉ុង | ១ គ.ក្រ | មានតំលៃ | ២.០០០៛ |
| - ត្រីឆ្លង់ស | ១ គ.ក្រ | មានតំលៃ | ១៦.០០០៛ |
| - ត្រីឆ្លង់ក្រហម | ១ គ.ក្រ | មានតំលៃ | ១៦.០០០៛ |
| - ត្រីក្បក | ១ គ.ក្រ | មានតំលៃ | ៨.០០០៛ |
| - ត្រីបបែល | ១ គ.ក្រ | មានតំលៃ | ៥.០០០៛ |
| - មឹក | ១ គ.ក្រ | មានតំលៃ | ៨.០០០៛ |
| - ត្រីឆ្លាម | ១ គ.ក្រ | មានតំលៃ | ៧.០០០៛ |

| | | | |
|---|---|---|---|
| - ត្រីអណ្ដែងប៉ុយ | ១ គ.ក្រ | មានតំលៃ | ៦.០០០៛ |
| - បង្គា | ១ គ.ក្រ | មានតំលៃ | ១៣.០០០៛ |
| - ក្ដាមថ្ម | ១ គ.ក្រ | មានតំលៃ | ១៥.០០០៛ |
| - ក្ដាមសេះ | ១ គ.ក្រ | មានតំលៃ | ១៨.០០០៛ |
| - ក្ដាមផ្ករលាន់ | ១ គ.ក្រ | មានតំលៃ | ៤.០០០៛ |

**ផ្នែកផលនេសាទត្រីទឹកសាប :**

| | | | |
|---|---|---|---|
| - ត្រីរ៉ស់ | ១ គ.ក្រ | មានតំលៃ | ១៥.០០០៛ |
| - ត្រីក្រាញ់ | ១ គ.ក្រ | មានតំលៃ | ៨.០០០៛ |
| - ត្រីកំភ្លៀញ | ១ គ.ក្រ | មានតំលៃ | ៦.០០០៛ |
| - ត្រីកន្ធរ | ១ គ.ក្រ | មានតំលៃ | ៨.០០០៛ |
| - ត្រីអណ្ដែង | ១ គ.ក្រ | មានតំលៃ | ១៣.០០០៛ |
| - អន្ទង | ១ គ.ក្រ | មានតំលៃ | ១៥.០០០៛ |

**១.៤.២. ខ្សែចង្វាក់ និងចរាចរផលិតផល :**

នៅក្នុងសង្កាត់ស្មាច់មានជ័យទាំងមូលភាគច្រើនប្រជាជនទិញអង្ករនៅក្នុងទីផ្សារ ឬមូលដ្ឋានយកមកផ្គត់ផ្គង់ជីវភាពគ្រួសារ ពីព្រោះប្រជាជននៅក្នុងសង្កាត់ពុំសូវមានអ្នកធ្វើស្រែចំការ បើពិនិត្យតាមតួលេខជាក់ស្ដែងប្រជាជនមានតែ ៥ គ្រួសារធ្វើស្រែ និងចំការ ដូចនេះការទិញអង្ករត្រូវការចាំបាច់ ។។

- ចំពោះចរាចរផលនេសាទនៅក្នុងសង្កាត់គឺអនុវត្តទៅតាមស្ថានភាពរបស់បងប្អូនអ្នកនេសាទដែលមានសកម្មភាព ដូចខាងក្រោម :
- ឈ្មួញប្រមូលទិញពីអ្នកនេសាទមកស្ដុកទុក
- ឈ្មួញប្រមូលទិញត្រីតាមទូកដឹកយកមកលក់នៅក្នុងទីផ្សារ ។

**១.៤.៣. ឱកាស និងឧបស័គ្គ**

សង្កាត់ស្មាច់មានជ័យមានធនធានព្រៃឈើជាច្រើន ដែលអាចផ្ដល់ផលប្រយោជន៍យ៉ាងច្រើនដល់ប្រជាជននៅក្នុងសង្កាត់ដូចជាផ្ដល់នូវទីជំរកសត្វព្រៃ ជារនាំងការពារខ្យល់ ការពារទឹកហូរច្រោះបាក់ដី និងបាតុភូតផ្សេងៗ អត្ថប្រយោជន៍ធនធានព្រៃឈើវាមានសារៈសំខាន់ណាស់សំរាប់មនុស្សយើងគ្រប់ៗគ្នាធ្វើអុសដុតធ្វើជំរកលំនៅដ្ឋាន ឬក៏អាចធ្វើឱសថថ្នាំព្យាបាលបានផងដែរ ។

ចំពោះធនធានជលផល គឺជាធនធានមួយដែលមានសក្ដានុពល យ៉ាងខ្ពស់ក្រៅពីការផ្គត់ផ្គង់ជាអាហារ គឺជាប្រភពចំណូលមួយយ៉ាងសំខាន់សំរាប់ប្រជាជន ក៏ដូចជាសេដ្ឋកិច្ចជាតិ តែបច្ចុប្បន្នការប្រើប្រាស់ធនធានធម្មជាតិមានការ ប៉ះពាល់

យ៉ាងខ្លាំង គឺធ្វើឱ្យធនធានទទួលរងនូវការគ្រោះថ្នាក់យ៉ាងខ្លាំង ដូចជាការកាប់ព្រៃលិចទឹក (កោងកាង) ការធ្វើ អាជីវកម្ម កាប់វាតយកដីព្រៃលិចទឹកយកលក់ ។

ការប្រើឧបករណ៍នេសាទខុសច្បាប់ ដូចជាមងក្រឡាតូច អាគុយឆក់ ដែលជាកត្តាប៉ុន្មានខាងលើធ្វើឱ្យធនធាន ធម្មជាតិក្នុងសង្កាត់ស្នាច់មានជ័យមានការថយចុះជាលំដាប់ ។

# ជំពូក ២

## ការវិភាគពីតម្រូវការសំរាប់អនាគត ឧបស័គ្គ និង សក្ដានុពល

### ២.១ តំបន់សើប

តំបន់ព្រៃការពារ និងវាលស្មៅដែលស្ថិតនៅនៅតំបន់ការពាររបស់ Wild Aid ជាតំបន់សំបូរដោយដីមានជីជាតិ គឺខ្ពង់រាបដែលមានជីវៈចំរុះយ៉ាងពិសេស និងជាកន្លែងជំរកសត្វព្រៃ។ តំបន់នេះត្រូវតែថែរក្សាជាតំបន់ព្រៃការពារដ៏ដែលដោយមិនអាចមានការពង្រីកដីកសិកម្មនៅក្នុងតំបន់ការពារនេះបានទេ។ ហើយសកម្មភាពរបស់មនុស្សឬការតាំងលំនៅដ្ឋានគឺត្រូវមានកំរិតកំណត់ជាទីបំផុតមិនអាចមានការអភិវឌ្ឍន៍ក្នុងទ្រុងទ្រាយធំបានឡើយ។ ទម្រង់នៃការប្រើប្រាស់ដីបច្ចុប្បន្នដែលគួររក្សាទុកជាព្រៃការពារដោយឥតមានការប្រែប្រួលមានៈ

- ក្រុមហ៊ុនព្រៃសម្បទាន ហ្គេត មានផ្ទៃដី ២៧៧៥ ហត (ប៉ុន្តែតំបន់នេះបានបញ្ចប់កិច្ចសន្យាជាមួយរដ្ឋាភិបាលរួចហើយ)។

### ២.២ ការប្រឈម/ឧបស័គ្គ

-ក្នុងសង្កាត់ស្នាច់មានជ័យមានបញ្ហាប្រឈមជាច្រើនតែបញ្ហាប្រឈមដែលមានពាក់ព័ន្ធដល់ធនធានធម្មជាតិក៏ដូចជាការគ្រប់គ្រងប្រើប្រាស់ដីមានដូចខាងក្រោមៈ

-ការកើនឡើងរបស់ប្រជាជនគឺជាការកើនឡើងនូវតំរូវការដែលកត្តាធ្វើឱ្យមានការប៉ះពាល់ដល់ការប្រើប្រាស់នូវធនធានធម្មជាតិ ប៉ុន្តែជាការពិតដែនព្រៃការពារមិនអាចរងនៅគ្រោះថ្នាក់នៃការបាត់បង់ព្រៃឈើបានឡើយ។

-ដោយយោលតាមស្ថានភាពដីបច្ចុប្បន្នត្រូវបាត់បង់ និងអាស្រ័យដោយការខូចខាតដីធ្វើស្រែចំការនិងដើម្បីបានដីមកធ្វើជាកម្មសិទ្ធិនោះធ្វើឱ្យជនខិលខូចឆ្លៀតឱកាសពង្រីកដីព្រៃ ដែលជាប់ព្រំប្រទល់ព្រៃការពារដោយមិនគិតពីផលប៉ះពាល់ឡើយ ។

-ការកាប់រុករានទន្រ្ទានព្រៃតំបន់ការពារយកដីមកធ្វើជាដីកម្មសិទ្ធិបច្ចុប្បន្នកំពង់មានសកម្មភាព គួឱ្យគាត់សំគាល់ព្រោះថានៅដំណាក់កាលប៉ុន្មានឆ្នាំចុងក្រោយនេះមានកើតបញ្ហាជាច្រើនដែលពាក់ព័ន្ធទៅនិងការកាប់បំផ្លាញព្រៃឈើយកដីធ្វើជាកម្មសិទ្ធិ ប៉ុន្តែផ្អែកទៅតាមការអនុវត្តច្បាប់របស់ស្ថាប័នជំនាញ និងអាជ្ញធ័រដែនដីភូមិ សង្កាត់សកម្មភាពនេះមានការថយចុះមកវិញយ៉ាងច្រើន ។

### ២.៣. កំណត់តំរូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្រ្តសង្កាត់ស្នាច់មានជ័យ :

#### ២.៣.១ គោលដៅនៃការអភិវឌ្ឍន៍

នៅក្នុងដំណើរការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្រ្ត សង្កាត់បានធ្វើការលើកនូវគំរោងផែនការសំរាប់ពេលអនាគត ដែលក្នុងនោះបានកំណត់នូវផែនការជាអាទិភាពដូចខាងក្រោម :

- ការសាងសង់ផ្លូវថ្នល់ ជាបឋមត្រូវបានកំណត់យកការជួសជុលផ្លូវចាស់ និងការកសាងផ្លូវថ្មីដែលក្នុងនោះរួមមានការធ្វើផ្លូវជីសការក្រាលគ្រួសក្រហមការធ្វើផ្លូវបេតុង ការធ្វើផ្លូវកៅស៊ូលើផ្លូវគ្រួសក្រហមដើម្បីធានាដល់ការប្រើប្រាស់នាពេលអនាគតយូរអង្វែង ។

- បច្ចុប្បន្ននៅក្នុងសង្កាត់ស្ទាច់មានជ័យទាំងមូលពុំទាន់ធានាបាននូវការប្រើប្រាស់ទឹកស្អាត និងការថែទាំសុខភាពអនាម័យនៅឡើយជាបណ្តើរៗការយល់ដឹងពីប្រជាជនបានកំពុងចាប់អារម្មណ៍ទៅការសាងសង់អណ្តូងទឹកហើយជាអាទិភាពសង្កាត់ក៏មានគំរោងផែនការសាងសង់អណ្តូងលូ អណ្តូងស្នប់ និងធុងចំរោះសំរាប់បំរើឱ្យការប្រើប្រាស់ទឹកស្អាត និងជំរុញការកសាងបង្គន់អនាម័យគ្រប់លំនៅដ្ឋានក្នុងមូលដ្ឋានសង្កាត់ ។

- នៅក្នុងការគាំទ្រលើការសិក្សាអប់រំ សង្កាត់បានកំណត់ជាគោលការណ៍ក្នុងការសាងសង់នូវអាគារសិក្សាបន្ថែមទៅលើសាលាចាស់ចំពោះសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ដោយឡែកចំពោះមត្តេយ្យសិក្សាសង្កាត់បានធ្វើការកំណត់ជ្រើសរើសទីតាំងក្នុងការសាងសង់សាលាថ្មីនៅតាមបណ្តាភូមិ ដើម្បីធានាដល់ការសិក្សារបស់កុមារតូចៗ ដែលជាមូលដ្ឋានគ្រឹះក្នុងការអប់រំជាមួយគ្នានេះដែរសង្កាត់នៅចាប់អារម្មណ៍ទៅលើការបើកថ្នាក់អក្ខរកម្មនៅតាមភូមិនៅពេលយប់ដោយប្រើប្រាស់សាលាមត្តេយ្យនេះ ។

- ចំពោះវិស័យសុខភាពសាធារណៈ នៅក្នុងសង្កាត់មានមន្ទីរពេទ្យបង្អែកខេត្តមួយសំរាប់បំរើសេវាកម្មជូនប្រជាជនឱ្យបានគ្រប់គ្រាន់ ដូច្នេះជាគោលការណ៍សង្កាត់បានលើកគំរោងផែនការសាងសង់ប៉ុស្តិ៍សុខភាពនៅតាមភូមិដែលស្ថិតនៅឆ្ងាយពីមន្ទីរពេទ្យបង្អែកខេត្ត ។

- នៅក្នុងការថែរក្សាធនធានធម្មជាតិ សង្កាត់បានចាប់អារម្មណ៍ទៅលើការស្តារបឹង អូរ ព្រែក និងការដាំព្រៃលិចទឹកឡើងវិញ (ព្រៃកោងកាង) ហើយនឹងការរៀបចំការបោះបង្គោលព្រំប្រទល់ព្រៃលិចទឹកឱ្យបាន ត្រឹមត្រូវនិងទាន់ពេលវេលាដើម្បីជៀសវាងការលួចជ្រៀតចូលពីសំណាក់ជនខិលខូចការអនុវត្តន៏ បាននូវយុទ្ធសាស្ត្រនេះវាអាចផ្តល់នូវផលប្រយោជន៏ យ៉ាងច្រើនដល់ប្រជាជននៅក្នុងសង្កាត់ក្នុងការបង្កើនប្រាក់ចំណូលតាមរយៈការដកយកផលពីធនធាន ។

### ២.៣.២ យុទ្ធសាស្ត្រអភិវឌ្ឍន៏

សំរាប់អាណត្តិទី ២ នេះក្នុងរយៈពេល ១៤ ខាងមុខក្រុមប្រឹក្សាសង្កាត់ស្ទាច់មានជ័យមានយុទ្ធសាស្ត្រមួយចំនួនសំរាប់អភិវឌ្ឍន៏មូលដ្ឋានសង្កាត់ដូចខាងក្រោមៈ

- ជំរុញការជួសជុលផ្លូវលំក្រាលគ្រួសថ្មភ្នំ
- ជំរុញការថែទាំផ្លូវលំអរធ្វើជាផ្លូវបេតុង ជំរុញការធ្វើផ្លូវអន្តរសង្កាត់
- ជំរុញធ្វើផ្លូវលំក្រាលគ្រួសក្រហម
- ជំរុញការធ្វើប្រព័ន្ធលូបង្ហូរទឹក
- ជំរុញការស្តាប្រឡាយទឹក និង ជំរុញការជីកប្រឡាយ
- ជំរុញអោយប្រជាពលរដ្ឋមានមុខរបរប្រកបអាជីវកម្មគ្រប់គ្នា

- ជំរុញការដាំដុះ និង ជំរុញការចិញ្ចឹមត្រី
- ជំរុញអោយប្រជាពលរដ្ឋមានការងារធ្វើគ្រប់ៗគ្នា
- ជំរុញអោយមានកន្លែងកំសាន្តទេសចរណ៍ធម្មជាតិ
- ជំរុញការសាងសង់សាលារៀន
- ជំរុញការថែរក្សាអនាម័យ និងលើកកំពស់ការថែរក្សាសុខភាព
- ធ្វើអោយប្រសើរឡើង និងបង្កើនលទ្ធភាពប្រកបដោយចិរភាពក្នុងការទទួលបាន និងប្រើប្រាស់ទឹកស្អាតអនាម័យបរិស្ថាន ជាពិសេសនៅតំបន់សហគមន៍ជនបទ ដែលរស់នៅខ្វះខាតទឹក។
- ធានាការគ្រប់គ្រងប្រកបដោយចិរភាពលើធនធានធម្មជាតិ និងបរិស្ថាន ដូចជាថែរក្សាព្រៃឈើ ជលផល ដីទឹក និងជីវៈចំរុះដែលពាក់ព័ន្ធទៅនឹងជីវភាពរស់នៅ និងសុខមាភាពមនុស្សសត្វ។

## ២.៤. គំរូវការសំរាប់អនាគត

### ២.៤.១ ប្រជាសាស្ត្រ

#### ២.៤.១.១. អត្រាកំណើន

ស្ថានភាពអត្រាកំនើនប្រជាជននៅក្នុងសង្កាត់ស្ទាច់មានជ័យបើពិនិត្យទៅមើលបណ្តាឆ្នាំនីមួយៗ ឃើញថាការកើនឡើងគួរឱ្យកត់សំគាល់ ព្រោះប្រសិនបើមើលទៅលើគ្រួសារមានការកើនឡើង តែបើការពិនិត្យទៅលើប្រជាជនបែជាមានការថយចុះទៅវិញដូចជាឆ្នាំ ២០០៥ មានចំនួនគ្រួសារ ១៩០៩ គ្រួសារ ឆ្នាំ ២០០៦ មាន ប្រជាជនចំនួន ១០.៣៥៥ នាក់ ឆ្នាំ ២០០៧ មានប្រជាជនចំនួន ១០.០៩៦ នាក់ ឆ្នាំ ២០០៨ មានប្រជាជនចំនួន ១០.៥៥៣ នាក់ កត្តាទាំងនេះតាមការសាកសួរព័ត៌មានគឺបណ្តាលមកពីការធ្វើចំណាកស្រុកចេញទៅរកមុខរបរនៅតាមបណ្តាខេត្តផ្សេង។ រីឯចំនួនគ្រួសារប្រជាជននៅក្នុងសង្កាត់មានការកើនឡើងទៅតាមបណ្តាឆ្នាំនីមួយៗ បើសិនយើងពិនិត្យមើលទៅលើកុមារក៏មានការកើនឡើងដែលអាចធ្វើឱ្យមានការកើនឡើងនូវកង្វះខាតទីកន្លែងសិក្សា ហើយក្នុងនោះដែរចំពោះដីធ្លីនៅក្នុងសង្កាត់ក៏មានការខ្វះខាតដីក្នុងការពង្រីកលើវិស័យកសិកម្មដែរ ដូច្នេះពីមួយឆ្នាំទៅមួយឆ្នាំប្រជាជនមានការកើនឡើងជាលំដាប់ជាកត្តាមួយត្រូវឱ្យយើងមានការកត់សំគាល់ទៅលើសក្តានុពលមួយចំនួនដូចជា លទ្ធភាពនៃការពង្រីកអាគារសិក្សា មុខរបរធ្វើស្រូវចំការការបង្កើននូវទិន្នផលកសិកម្មការអភិរក្សនូវធនធានធម្មជាតិ និង កំណត់នៃការប្រើប្រាស់ធនធានឱ្យបានសមស្របទើបអាចធានាបាននូវអត្រាកំណើន ។

**តារាងការគណនាអត្រាកំណើនមធ្យម**

| ចំនួនគ្រួសារប្រជាជន | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | អត្រាកំណើនមធ្យម | កំណើន/ឆ្នាំ |
|---|---|---|---|---|---|---|---|
| ចំនួនគ្រួសារសរុប | ១៦៩៩ | ១៩០៩ | ១៩៣៧ | ១៩២១ | ២០៥២ | - | ១០៣ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| អត្រាកំណើនគ្រួសារ | - | ១២.៤% | ១.៥% | -០.៨% | ៦.៨% | ៥% | - |
| ចំនួនប្រជាជនសរុប | ៨៦២៤ | ១០០៩២ | ១០៣៥៥ | ១០០៩៥ | ១០៥៥៣ | - | ៥៧០ |
| អត្រាកំណើនប្រជាជន | - | ១៧.០% | ២.៦% | -២.៥% | ៤.៥% | ៥.៤% | - |

ប្រភព : សៀវភៅឯកសារព័តិមានស្ថានភាពឃុំ ឆ្នាំ ២០០៩

### ២.៤.១.២. ការធ្វើចំណោលប្រជាសាស្ត្រ

**តារាងការធ្វើចំណោលប្រជាសាស្ត្រ**

| ស្ថិតិតាមក្រុមអាយុ | ឆ្នាំ ២០១២ | | ឆ្នាំ ២០១៧ | | ឆ្នាំ ២០២២ | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុក្រោម០-២ឆ្នាំ | ៤៣៩ | ២១៣ | ៥៣៦ | ២៦០ | ៦៣៣ | ៣០៧ |
| អាយុ ៣-៥ឆ្នាំ | ១១៥២ | ៥៨៦ | ១៤០៨ | ៧១៦ | ១៦៦៤ | ៨៤៦ |
| អាយុពី ៦-១១ឆ្នាំ | ២២៤៩ | ១១៥៥ | ២៧៤៨ | ១៤១១ | ៣២៤៧ | ១៦៦៧ |
| អាយុពី ១២-១៤ឆ្នាំ | ១២០៩ | ៦៦៤ | ១៤៧៨ | ៨១២ | ១៧៤៧ | ៩៦០ |
| អាយុពី ១៥-១៧ឆ្នាំ | ១០៧៥ | ៦១០ | ១៣១៤ | ៧៤៦ | ១៥៥៣ | ៨៨២ |
| អាយុពី ១៨-២៤ឆ្នាំ | ១៥១០ | ៧៥៣ | ១៨៤៥ | ៩២០ | ២១៨០ | ១០៨៧ |
| អាយុពី ២៥-៦០ឆ្នាំ | ៤៩៤៤ | ២៦១៧ | ៦០៤២ | ៣១៩៨ | ៧១៤០ | ៣៧៧៩ |
| អាយុពី ៦១ឆ្នាំឡើងទៅ | ២៥៥ | ១៣០ | ៣១២ | ១៥៩ | ៣៦៩ | ១៨៨ |
| ចំនួនប្រជាជនសរុប | **១២៨៣៣** | **៦៧២៨** | **១៥៦៨៣** | **៨២២២** | **១៨៥៣៣** | **៩៧១៦** |
| គ្រួសារ | **២៤៩៦** | | **៣០៥១** | | **៣៦០៥** | |

អត្រាកំណើនប្រជាជននៅក្នុងសង្កាត់ស្ទាច់មានជ័យ បើពិនិត្យទៅលើកំណើនក្នុងរយៈពេល ៥ ឆ្នាំម្តង សំរាប់រយៈពេល ១៥ ឆ្នាំខាងមុខ ឃើញថាអត្រាកំនើនប្រជាជនមធ្យម ៥.៤% ស្មើនឹង ៥៧០ នាក់ ក្នុងមួយឆ្នាំ នឹងមាន ៥% ស្មើនឹង ១០៣គ្រួសារក្នុងមួយឆ្នាំ។ នោះបើពិនិត្យទៅលើបរិមាណផ្ទៃដីដែលអាចប្រើប្រាស់បានទៅមានក៏រិត ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏យើងត្រូវចាប់អារម្មណ៏ដល់ការអភិវឌ្ឍន៏ដែរ ។ ព្រោះអត្រាកំណើនរបស់ប្រជាជននៅក្នុងសង្កាត់ស្ទាច់មានជ័យ គឺវាពាក់ព័ន្ធទៅលើការអភិវឌ្ឍន៏ ធនធានដែលមាននៅក្នុងសង្កាត់ពិសេសបរិមាណដីដែលអាចបង្កើននូវបរិមាណផល ដើម្បីធានាស្បៀងក្នុងតំបន់ ។

### ២.៤.២ គំរូខតារដីសំរាប់លំនៅដ្ឋាន

ចំពោះដីលំនៅដ្ឋាន គឺសំដៅទៅដល់ដីដែលប្រើប្រាស់សំរាប់សង់ផ្ទះ និងសំរាប់ដាំដំណាំសួនគ្រួសារនៅ ជុំវិញ

(លំអិតសូមមើលឧបសម្ព័ន្ធ ១) សំរាប់ឆ្នាំគោល ២០០៨ មានទំហំ ៥.៧៤៨,១៩២ ហិកតា សំរាប់ប្រជាជនប្រមាណ ១៩៩៨[1] គ្រួសារ ដូច្នេះទំហំដីសំរាប់មួយគ្រួសារគិតជាមធ្យមគឺមាន ០,២០ ហិកតា ។ ដែលទំនេរនេះអាចជាទំហំសមស្របសំរាប់ការតាំងលំនៅដ្ឋាន

- តំរូវការសំរាប់ឆ្នាំ ២០២២ គឺមាន :
- ចំនួនគ្រួសារបច្ចុប្បន្នមិនទាន់មានដីលំនៅដ្ឋាន ៥៤ គ្រួសារ x០,២០= ១០,៨ហត
- កំនើនគ្រួសារ ២០២២ = ១៥៥៣ គ្រួសារ x ០,២០ = ៣១០,៦

**សរុប = ៣២១,៤ហត**

### ២.៤.៣ តំរូវការដីកសិកម្ម

សង្កាត់ស្វាច់មានជ័យមានសង្កាត់មួយ ស្ថិតនៅក្នុងតំបន់ទីប្រជុំជនដូចនេះប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរជាច្រើនដូចជា នេសាទ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ មុខជំនួញ ជាបុគ្គលិករបស់ក្រុមហ៊ុនឯកជន និងជាមន្ត្រីរាជការក្នុងក្របខណ្ឌរបស់រដ្ឋ..។ ក្នុងចំណោមប្រជាពលរដ្ឋ ២០៥២ គ្រួសារដែលប្រកបមុខរបរខាងលើក៏នៅមានប្រជាពលរដ្ឋចំនួន ៥ គ្រួសារដែរ ដែលប្រកបមុខរបរធ្វើស្រូវជាចំបង (ដីស្រែរបស់ពួកគាត់ស្ថិតនៅក្នុងតំបន់ព្រៃការពារអភិរក្ស Wide Aid)។ ដើម្បីអោយស្របអនុក្រិតលេខ ៧២ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់ និងដើម្បីរក្សាបាននូវមុខរបររបស់ប្រជាពលរដ្ឋចំនួន ៥ គ្រួសារធ្វើស្រែវស្សា និងដើម្បីគណនារកកំណើនប្រជាពលរដ្ឋដល់ ឆ្នាំ ២០២២ ដែលធ្វើស្រែវស្សា សង្កាត់បានរកដីទុកសំរាប់ធ្វើស្រែវស្សាដូចខាងក្រោម :

តំរូវការដីសំរាប់ឆ្នាំ ២០២២ គឺមាន :

- ចំនួនគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីកសិកម្ម ៥ គ្រួសារ x ២ហត =១០ ហត
- កំណើនគ្រួសារ ២០២២ = ៤ គ្រួសារ x ២ ហត = ៨ហត

**សរុប = ១៨ ហត**

ខាងលើនេះជាការវិភាគដោយកំណត់ទំហំដីសំរាប់ធ្វើការដំណាំស្រូវរបស់ប្រជាកសិករ។ បើយើងពិនិត្យទៅលើទិន្នផលស្រូវឃើញថាមាន ២ តោនក្នុងមួយហិចតាកាលពីឆ្នាំ ២០០៧ (ព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០០៩) ប្រជាជនម្នាក់ៗត្រូវការអង្ករ ១៤៣ គ.ក្រ ស្មើ ២២៤ គ.ក្រ ស្រូវ/ឆ្នាំ (ការិយាល័យកសិកម្មស្រុក)។ ទំហំដីដែលបានកំណត់ខាងលើមានចំនួន ១០ហត អាចទទួលផលស្រូវបានចំនួន ២០ តោន តំរូវការជាក់ស្តែងចំនួន ២.៣៦៣ តោន ខ្វះពីតំរូវការចំនួន ២.៣៤៦ តោន។ ឯកំណើនប្រជាពលរដ្ឋរហូតដល់ឆ្នាំ ២០២២ មាន ១៨៥៣៣ នាក់តំរូវការស្រូវចំនួន ៤.១៥១តោនស្មើនឹង ២.៦៥០ តោនអង្ករ។ ដូច្នេះដើម្បីអោយផលស្រូវមានសមតុល្យជាមួយនឹងចំនួនប្រជាពលរដ្ឋនៅឆ្នាំ ២០២២ យើងត្រូវពង្រីកផ្ទៃដីដាំដំណាំស្រូវចំនួន ៨ ហត ថែមទៀតសរុបផ្ទៃដីចាស់ ១០ ហតទាំងអស់ស្មើនឹង ១៨ ហត ទទួលបានផលស្រូវ ៣២ តោន និងត្រូវទិញអង្ករពីខាងក្រៅចំនួន ២.៦២៩,៥តោន ស្មើនឹង ៤១១៩ តោន។

### ២.៤.៤ តំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ

ដោយនៅសង្កាត់ស្នាច់មានជ័យនៅមានព្រៃលិចទឹក និងវាលស្មៅសំបូរបែបនៅឡើយ ដូច្នេះដីដែលនៅក្នុងតំបន់រសើប និងដីផ្សេងៗទៀតដែលមិនបានកំណត់ទៅក្នុងប្រភេទប្រើប្រាស់ដីផ្សេងៗទៀត គឺត្រូវទុកឱ្យនៅជាដីព្រៃ និងវាលស្មៅដែលស្ថិតនៅក្នុងនាទីព្រៃលិចទឹកដដែល សំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ពិសេសគឺបណ្តុំបឹងបួរធម្មជាតិដែលជាប្រភពដ៏ចំបងនៃធនធានជលផល ដើម្បីធានាបាននូវតំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ នោះគឺចាប់អារម្មណ៍ទៅលើការការពារ និងទប់ស្កាត់ឱ្យបានជាដាច់ខាត នូវការលួចកាប់រំលោភយកដីខាងលើពីជនខិលខូច និងចាត់វិធានការឱ្យបានខ្លាំងក្លាជាទីបំផុតសំរាប់ជនទាំងនោះ ។

### ២.៤.៥. តំរូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម

ជារួមហេដ្ឋារចនាសម្ព័ន្ធសង្គមក្នុងរូបភាពតូចតាច គឺត្រូវបានបញ្ចូលទៅក្នុងដីលំនៅដ្ឋាន ឬដីទីប្រជុំជន ដោយមិនបានញែកចេញដោយឡែកនោះទេ (ក្នុងនោះដីកប់ខ្មោច វត្តអារាម សាលាឆទាន ក៏គិតគូរក្នុងនោះដែរ) តែក្នុងនោះក៏មានការគិតគូរជារួម លើកលែងតែហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមានទ្រង់ទ្រាយធំ ទើបមានការគិតគូរដោយឡែក និយាយរួមដីសំរាប់តំរូវការហេដ្ឋារចនាសម្ព័ន្ធត្រូវបានកំណត់ជារួម ជាមួយនឹងដីត្រៀមបំរុងសំរាប់ទីប្រជុំជន ។

តាមការប៉ាន់ប្រមាណជាសរុប ដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម គឺមានតំរូវការបន្ថែមចំនួន ០ហិកតា ចំពោះផ្លូវទំនប់តូចៗ គឺមិនមានការគិតគូរជាផ្ទៃដីទេ តែមានប្រវែង ហើយនឹងបង្ហាញក្នុងផែនទីដោយឡែក ។

**តារាងផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទូទៅ :**

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំនេះ | ចំនួន ១៥ ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | ២ បន្ទប់ | ២៩ បន្ទប់ | ២៧ បន្ទប់ |
| សាលាបឋមសិក្សា | ៤៣ បន្ទប់ | ៧៦ បន្ទប់ | ៣៣ បន្ទប់ |
| សាលាអនុវិទ្យាល័យ | ៥ បន្ទប់ | ៤៥ បន្ទប់ | ៤០ បន្ទប់ |
| សាលាវិទ្យាល័យ | ២២ បន្ទប់ | ៣៨ បន្ទប់ | ១៦ បន្ទប់ |
| មណ្ឌលសុខភាព | ១ | ១ | ០១ |
| ប៉ុស្តិ៍សុខភាព | ០ | ០ | ០ |
| ស្នាក់ការសហគមន៍នេសាទ | ០ | ០ | ០ |
| ស្រះទឹកស្អាត | ១០ | ០ | ០ |
| អណ្តូងទឹកស្អាត | ៣៣៣អណ្តូង | ៥៨៥ អណ្តូង | ២៥២ អណ្តូង |
| កន្លែងចាក់សំរាម | ១កន្លែង | ០ | ០ |
| ទីតាំងផ្សារ | ០ | ០ | ០ |
| ប៉ុស្តិ៍នគរបាល | ១ កន្លែង | ០ | ០ |

| | | | |
|---|---|---|---|
| មន្ទីរពេទ្យបង្អែកខេត្ត | ១ កន្លែង | 0 | 0 |

ប្រភព :បានមកពីទិន្នន័យឃុំ ២០០៩




រូបភាព ៥ : មន្ទីរពេទ្យបង្អែក សង្កាត់ស្មាច់មានជ័យ

### ២.៤.៥.១ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព

ផ្អែកតាមសភាពជាក់ស្តែងនៃបរិមាណផ្លូវ ដែលមានក្នុងសង្កាត់ឃើញថាផ្លូវមួយចំនួនត្រូវធ្វើការកែលំអ ដូចជា ផ្លូវគ្រួសក្រហមដែលបានសាងសង់ពីមុនមកបច្ចុប្បន្នត្រូវខូចហើយនៅក្នុងឆ្នាំ ២០០៩នេះសង្កាត់បានធ្វើការជួសជុលឡើងវិញមានប្រវែងសរុប ១៩៥០ម ហើយនៅសល់ពីនោះសង្កាត់នឹងធ្វើការជួសជុលបន្ត រយះពេល១៥ឆ្នាំខាងមុខ សង្កាត់នឹងលើកគំរោងសាងសង់ផ្លូវក្រាលគ្រួសក្រហមបន្ថែមលើផ្លូវដីសប្រវែង ៣៥៨៧ម ជាមួយគ្នានេះដែរសង្កាត់ក៏បានលើកគំរោងផ្លូវចាក់បេតុង និងផ្លូវកៅស៊ូលើផ្លូវក្រាលគ្រួសក្រហម ដែលស្ថិតនៅជាប់ផ្លូវជាតិលេខ ៤៨ តភ្ជាប់ពីផ្លូវទៅសាលាក្រុងត្រង់ចំណុចមុខវត្តពេទនិមិត្ត (ហៅវត្តថ្មី) ចេញពីផ្លូវជាតិលេខ ៤៨ ដែលមានប្រវែង ១,០៦ គម ។

នៅក្នុងដំណើរការអភិវឌ្ឍន៏ទៅលើប្រព័ន្ធទឹក សង្កាត់បានធ្វើការសិក្សាទៅលើប្រភពទឹកដែលមានស្រាប់ ដោយផ្អែកទៅលើស្ថានភាពភូមិសាស្រ្ត និងលទ្ធភាពអំណោយផលរបស់សង្កាត់ស្មាច់មានជ័យ នោះសង្កាត់លើកគំរោងផែនការអភិវឌ្ឍន៏សំរាប់រយះពេល ១៥ ឆ្នាំខាងមុខដោយធ្វើការសាងសង់លូជ្រុង និង លូមូលដើម្បីបញ្ចៀសទឹកភ្លៀងនូវរដូវវស្សា ។

បច្ចុប្បន្នលូឆ្លងផ្លូវនៅក្នុងសង្កាត់ស្ទាច់មានជ័យ មានាករខូចខាតមួយចំនួន ដោយសារផ្លូវគ្រួសក្រហម ត្រូវខូចខាតធ្វើឱ្យលូខូចបែក និងលុបដីជិតមិនអាចប្រើការបាន ដូច្នេះតំរូវការក្នុងពេលអនាគតតំរូវការមានការសាងសង់ លូឆ្លងផ្លូវ និង លូដោះទឹកចំនួន។

**តារាងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត**

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំនេះ (គ.ម) | ប្រវែងផ្លូវ ១៥ ឆ្នាំ (គ.ម) | បំរែបំរួល |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ( ផ្លូវជាតិ ) | ៩.៦៤៩ | 0 | 0 |
| ផ្លូវក្រាលកៅស៊ូ( ផ្លូវខេត្ត ) | ៨.២៤៩ | ១៦.៣០៥ | ៨.0៥៦ |
| ផ្លូវចាក់បេតុង | ៣.២៣២ | ១៦៩២២ | ១៣៦៩0 |
| ផ្លូវក្រាលគ្រួសក្រហម | ៤0.៧៣៣ | ៤៤៣២0 | ៣៥៨៧ |
| ជួសជុលផ្លូវគ្រួសក្រហម | 0 | 0 | ២៧0៧ |
| ប្រវែងផ្លូវដីស | ៩.៥00 | 0 | 0 |
| ប្រវែងផ្លូវថ្មើជើង | ៣៦.0៩១ | 0 | 0 |
| ចំនួនលូជ្រុង | 0៥កន្លែង ៦៦ម | 0 | 0 |
| ចំនួនលូ | ៤0កន្លែង ៣៧0ម | ៤៤ កន្លែង | ៤ កន្លែង |
| ស្ពានបេតុង | 0.៧៥៤ | 0 | 0 |

**២.៤.៥.២ តំរូវការដីសាលារៀន**

ផ្ទៃដីសំរាប់កសាងសាលារៀននៅក្នុងសង្កាត់ស្ទាច់មានជ័យគឺមិនមានការកំណត់ផ្ទៃដីឱ្យបានច្បាស់លាស់ នោះទេដោយកន្លងមកដីសាលារៀនត្រូវបានគិតគូរបញ្ចូលទៅក្នុងដីភូមិ ហើយប្រសិនបើតំរូវការឱ្យមានការសាងសង់ បន្ទប់រៀនថ្មី គឺអាចធ្វើការសាងសង់នៅក្នុងបរិវេណសាលាចាស់បានលើកលែងតែមានការសាងសង់សាលាថ្មី ។

ចំពោះការអភិវឌ្ឍន៍ និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសង្គម នៅក្នុងមូលដ្ឋានសង្កាត់ស្ទាច់មានជ័យ បច្ចុប្បន្ននៅមានកំរិតដោយជាបណ្តើ១កំពុងដំណើរការអភិវឌ្ឍន៍ ដូចជានៅចុងឆ្នាំ ២00៨ និងដើមឆ្នាំ ២00៩ មានការ សាងសង់អនុវិទ្យាល័យ១ កន្លែង និងមួយអគារទើបកើតថ្មីទៀត ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយក៏ការអភិវឌ្ឍន៍លើវិស័យ អប់រំនៅក្នុងសង្កាត់ស្ទាច់មានជ័យនៅមិនទាន់បំពេញតំរូវការរបស់សិស្សានុសិស្សនៅឡើយ ដូច្នេះសង្កាត់យើងខ្ញុំនឹងលើក នូវគំរោងផែនការ ១៥ ឆ្នាំ ខាងមុខ តំរូវការលើកអាគារផ្នែកតាមបរិមាណសិស្សានុសិស្ស គឺសាលាមត្តេយ្យ សាលាបឋម សិក្សាក៏ដូចអនុវិទ្យាល័យ និងវិទ្យាល័យ បើពិនិត្យទៅឬក៏គណនាតាមកំនើនប្រជាពលរដ្ឋឃើញថាតំរូវការទាំងនេះអាច ផ្តល់ឱ្យកាសឱ្យសង្កាត់យើងខ្ញុំអាចអភិវឌ្ឍន៍ទៅតាមលទ្ធភាពជាបណ្តើរ១ ដែលនៅក្នុងនោះសាលាមត្តេយ្យ ៥ អាគារនៅ ក្នុង ភូមិ ១ ភូមិ៣ និង ភូមិស្ទាច់មានជ័យ និងភូមិបឹងឃុនឆាងង ហើយនឹងសាលាបឋមសិក្សាសង្កាត់មានគំរោងពង្រីក ៦

អគារស្មើ ៣៣បន្ទប់នៅក្នុងដីសាលាចាស់ដែលមានស្រាប់ ផ្នែកអនុវិទ្យាល័យសង្កាត់មានគំរោងពង្រីកបន្ថែមទៀតដែរ ចំនួន ៨ អគារស្មើ ៤០ បន្ទប់នៅក្នុងដីសាលាចាស់ ចំពោះសាលាវិទ្យាល័យវិញ សង្កាត់ក៏មានគំរោងពង្រីកថែមទៀតចំនួន ៣អគាស្មើ១៦បន្ទប់នៅក្នុងដីសាលាចាស់ដែរ ។

**តារាងកំណើនកុមារ និងថ្នាក់រៀន និងសាលានៅឆ្នាំ ២០១២-២០២២**

| ប្រភេទសាលា | នៅឆ្នាំ ២០១២ | | | នៅឆ្នាំ ២០១៧ | | | នៅឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយ្យសិក្សា | ១១៥២ | ២ | ១០ | ១៤០៨ | ១ | ៥ | ១៦៦៤ | ២ | ១២ |
| ថ្នាក់បឋមសិក្សា | ២២៤៩ | -៤ | -២១ | ២៧៤៨ | ១ | ៧ | ៣២៤៧ | ៥ | ២៦ |
| ថ្នាក់អនុវិទ្យាល័យ | ១២០៩ | ១ | ៧ | ១៤៧៨ | ២ | ៨ | ១៧៤៧ | ៥ | ២៥ |
| ថ្នាក់វិទ្យាល័យ | ១០៧៥ | -២ | -១១ | ១៣១៤ | ០ | ២ | ១៥៥៣ | ៣ | ១៤ |

### ២.៤.៥.៣ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត

**ក. សេវាកម្មសុខភាព**

- ស្ថិតនៅក្នុងដំណាក់កាលនេះសង្កាត់ស្មាច់មានជ័យពុំទាន់មានប៉ុស្តិ៍សុខភាពនៅតាមភូមិ សំរាប់ជួយសំរួលក្នុងការទ្រទ្រង់សុខមាភាពរបស់ប្រជាជនបន្ថែមពីលើមន្ទីរពេទ្យបង្អែកខេត្ត ។

- ចំងាយមធ្យមពីភូមិទៅបង្អែកខេត្តមានចំងាយ៥គីឡូម៉ែត្រសំរាប់ភូមិបឹងឃុនឆាងតែមួយ ដោយឡែកភូមិ៤ទៀតមានចំងាយពី១ឬ២គីឡូម៉ែត្រតែប៉ុណ្ណោះ ។

- ផ្អែកទៅតាមស្ថានភាពភូមិបឹងឃុនឆាងដែលមានប្រជាជនរស់នៅដាច់ឆ្ងាយពីគេ និងមានចំងាយផ្លូវឆ្ងាយពីមន្ទីរពេទ្យបង្អែកបណ្តាលឱ្យមានការលំបាកក្នុងការធ្វើដំណើរ ដូច្នេះការផ្តល់សេវាកម្មផ្នែកសុខភាពមិនទាន់គ្រប់គ្រាន់នៅឡើយ ។

- ចំពោះការការពារសុខមាភាពក្នុងសង្កាត់ស្មាច់មានជ័យនូវចោទជាបញ្ហាហើយនៅរយៈពេល១៥ឆ្នាំខាង មុខក៏នៅជាបញ្ហាដដែល ។

- ដូច្នេះជាអាទិភាពសង្កាត់ត្រូវលើកផែនការការសាងសង់ប៉ុស្តិ៍សុខភាពឱ្យមាននៅតាមភូមិ នីមួយៗទើបអាចជួយសំរួលដល់ការលំបាក លើការថែទាំសុខភាពក្នុងមូលដ្ឋាន សំរាប់ផែនការអនាគត ។

**ខ. ការផ្គត់ផ្គង់ទឹកស្អាត**

ការប្រើប្រាស់ទឹកស្អាត់នៅក្នុងសង្កាត់ស្មាច់មានជ័យ បច្ចុប្បន្ននៅតែជាបញ្ហានៅឡើយព្រោះថា

ចំពោះអណ្តូងទឹកនិងស្រះទឹកនៅក្នុងសង្កាត់ ដែលបានសាងសង់ពីមុននោះមួយចំនួនត្រូវបានបាក់បែកខូចខាតដូច្នេះជាជំហ៊ានដំបូងនៃការអភិវឌ្ឍន៍ត្រូវស្តារនិងជួសជុលនូវប្រភពទឹកស្អាតទាំងនេះ ហើយជាផែនការនៅពេលអនាគតសង្កាត់ត្រូវបន្ថែមនូវ គំរោងផែនការក្នុងការជីកស្រះស្តុបទឹកស្អាត និងអណ្តូងទឹកស្អាតព្រមទាំងផ្តល់ជូនធុងចំរោះ ។

ដើម្បីធានាបាននូវការប្រើប្រាស់ទឹកស្អាត ដែលរួមមានអណ្តូងស្នប់ចំនួន 0 អណ្តូងលូចំនួន ២០៨ អណ្តូង និង ជីកស្រះទឹកស្អាតចំនួន 0 ស្រះ សំរាប់ភូមិ 0ភូមិ និងផ្តល់ធុងចំរោះនៅភូមិ 0 ក្នុង ១ គ្រួសារ ១ ធុង ។

### ២.៤.៥.៤ ផ្នែកវប្បធម៌ និងសាសនា

នៅក្នុងការអភិវឌ្ឍន៍ទៅលើវិស័យវប្បធម៌ ជាកត្តាមួយចូលរួមចំណែកជំរុញឱ្យមានសន្ទុះដល់ការអប់រំផ្នែកព្រះពុទ្ធសាសនា រាល់ទីតាំងនីមួយៗតាមបណ្តាភូមិត្រូវបានផ្តល់លទ្ធភាព និងជួយសំរួលដល់ប្រជាជននៅតាមមូលដ្ឋានផ្ទាល់ដើម្បីមានឱកាសចូលរួមពង្រីកដល់ការផ្សព្វផ្សាយតាមរយៈការអប់រំដល់យុវជនដែលជាសរសរទ្រូងនៃប្រទេសជាតិឱ្យជៀសផុតពីអំពើខុសច្បាប់ទាំងឡាយដែលរដ្ឋាភិបាលបានកំណត់។ ជាអាទិភាពសំរាប់សង្កាត់ស្នាច់មានជ័យបច្ចុប្បន្ន សំរាប់កន្លែងគោរពប្រពៃណីសាសនានាថ្ងៃអនាគត ពុំទាន់មានតំរូវការបន្ថែមឡើយ ។

**តារាងការអភិវឌ្ឍន៍ និងអភិរក្សផ្នែកវប្បធម៌ និងសាសនា**

| វប្បធម៌ និងសាសនា | ចំនួនក្នុងឆ្នាំនេះ | ចំនួន ១៥ ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាឆទាន | 0 | 0 | 0 |
| ទីកន្លែងសក្ការៈបូជា | ២ | 0 | 0 |
| វត្តអារាម | ២ | 0 | 0 |
| ផ្សេងៗ | | | |

# ជំពូក ៣
# ផែនការប្រើប្រាស់ដីអនាគត

## ៣.១. ស្ថានភាពដី សក្តានុពលដី និងតំរូវការដី

### ៣.១.១. ស្ថានភាពដីទូទៅ និងសក្តានុពល

នៅក្នុងសង្កាត់ស្ទាច់មានជ័យ ធនធានដែលមានស្រាប់អាចផ្តល់នូវសក្តានុពលដល់ការប្រើប្រាស់ និង អភិរក្ស អភិវឌ្ឍន៍ទៅលើធនធានទាំងនោះ ឱ្យមាននិរន្តភាពដែលក្នុងនោះរួមមានដូចជា : ស្ថានភាពដីនៃនាទីព្រៃលិចទឹកគឺជាបរិស្ថានធម្មជាតិដ៏ល្អប្រសើរសំរាប់មជ្ឍដ្ឋានរស់នៅ នៃធនធានជលផលនៅក្នុងតំបន់នោះ នៅក្នុងក្របខណ្ឌនៃការរស់នៅរបស់ពពួកភាវរស់គឺជាបណ្តាញនៃប្រព័ន្ធអេកូឡូស៊ី នៅក្នុងមជ្ឍដ្ឋាននាទីព្រៃលិចទឹក ដែលបានផ្តល់នូវសារប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ជាអាទិ៍ដូចជាព្រៃលិចទឹកផ្តល់នូវទីជំរកដល់ពពួកភាវរស់ និងសត្វផ្សេងៗដែលរស់នៅក្នុងព្រៃលិចទឹក ដូចជាពពួកត្រី បង្កា ក្តាម ងាវ ។ល។ ទាំងនោះគឺជាសក្តានុពលមួយដែលផ្តល់នូវសារប្រយោជន៍ដល់ប្រជាជនរស់នៅក្នុងមូលដ្ឋាន សំរាប់ការដកយកផលពីព្រៃលិចទឹក ដូចជាយកមកធ្វើផ្ទះ និងជារបាំងការពារខ្យល់ ។

**តារាងតំរូវការនៃការប្រើប្រាស់ដីអនាគត**

| ប្រើប្រាស់ដី | ក្រឡាផ្ទៃឆ្នាំនេះ (ហ.ត) | ក្រឡាផ្ទៃ ១៥ ឆ្នាំ (ហ.ត) | បំរែបំរួល (ហ.ត) |
|---|---|---|---|
| ចំការដំណាំលើដីភូមិចាស់ | ១៦៩.៤៦ | ០ | ០ |
| តំបន់ទេសចរណ៍ធម្មជាតិ | ០ | ១៥០ | ១៥០ |

### ៣.១.២ តំរូវការដីតាមប្រភេទ

ដោយយោងតាមការគណនាអំពីចំណោលប្រជារាស្ត្រនៅក្នុងជំពូក២នៅសៀវភៅការប្រើប្រាស់ដីសង្កាត់ស្ទាច់មានជ័យនោះនឹងឃើញចំនួនប្រជាជនក៏ដូចជាចំនួនគ្រួសារមានការកើនឡើងអត្រាកំនើនប្រជាជនគឺជាការកើនឡើងនូវតំរូវការនៃការប្រើប្រាស់ទៅលើធនធានគ្រប់ប្រភេទ ដូច្នេះដើម្បីធានាឱ្យមាននិរន្តរភាពរវាងមនុស្ស និងធនធានដែលមានស្រាប់ក្នុងរយៈពេល ១៥ ឆ្នាំ សង្កាត់មានគំរោងផែនការដូចខាងក្រោម :

- ពង្រីកដីសំរាប់សាងសង់លំនៅដ្ឋានចំនួន ៣២១ ហិកតា (លំនៅដ្ឋានទីប្រជុំជន-លំនៅដ្ឋានភូមិ) តាមសងខាងផ្លូវជាតលេខ ៤៨ តាមសងខាងផ្លូវភូមិ ៣ តាមសងខាងផ្លូវភូមិស្ទាច់មានជ័យ និងតាមសងសាងផ្លូវភូមិ បឹងឃុនឆាង និងផ្លូវដទៃទៀត ចំពោះដីសំរាប់សាងសង់លំនៅដ្ឋាននោះ គឺយើងបានជ្រើសរើសយកតាមភាពសមស្របរបស់ដីមានន័យថាដីដែលពុំសូវសំបូរជីវជាតិ ។

- ដីសំរាប់បញ្ចុះសព្វមានចំនួន ០១ កន្លែង

- នៅក្នុងការពង្រីកដីវាលស្រែរបស់សង្កាត់ស្ទាចមានជ័យគឺជាការចាប់អារម្មណ៍ទៅលើដីវាលស្រែដែលបានបោះបង់ចោល ធ្វើឱ្យក្លាយទៅជាវាលស្មៅ និងដីទំនាបដទៃទៀត ដែលអាច ធ្វើស្រែបានមានចំនួន ១៨ ហ.ត ។ ដីស្រែខាងលើនោះធ្វើស្រែបានលុះត្រាតែមានទឹកភ្លៀង ។

- ដីចំការដាំណាំរយៈពេលខ្លី គឺត្រូវការបញ្ចូលទៅក្នុងដីសំរាប់សាងសង់លំនៅដ្ឋានរួចហើយ ។

- ដីចំការដាំណាំឈើហូបផ្លែបាន លុះត្រាតែដីនោះជាប្រភេទដីក្រហម មានជីវជាតិស្ថិតនៅតំបន់ខ្ពង់រាប បើតាមពិនិត្យឱ្យជាក់ស្តែងដីក្រហមមានជីវជាតិស្ថិតនៅខ្ពង់រាបមានចំនួនមួយកន្លែងគត់មានផ្ទៃដីប្រមាណ ជា ៧១៨ ហ.ត នៅភាគខាងកើត នៃភូមិសាស្រ្តសង្កាត់ស្ទាចមានជ័យ រីឯដីក្រៅពីតំបន់ខ្ពង់រាបខាងលើគឺជាតំបន់វាលទំនាប ជាប្រភេទដីខ្សាច់ខ្សោះជីវជាតិ មិនអាចដាំដំណាំឈើហូបផ្លែបានទេ ។ ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំខាងមុខសង្កាត់មានគំរោងពង្រីកដីសំរាប់ដាំដំណាំឈើហូបផ្លែថែមទៀត ។

- ដីព្រៃលិចទឹក គឺជាកត្តាសំខាន់សំរាប់ការពារថែរក្សា អភិរក្ស និងអភិវឌ្ឍន៍ទៅលើធនធានធម្មជាតិកន្លងមក ដោយសារការយល់ដឹងរបស់ប្រជាជននៅមានកំរិតរួមផ្សំនឹងកំរិតជីវភាពផងនោះ ប្រជាជនបានកាប់បំផ្លាញព្រៃលិចទឹកជាច្រើនដូចជាព្រៃកោងកាង និងព្រៃលិចទឹកឯទៀតៗ ។

ដូច្នេះដើម្បីឱ្យព្រៃលិចទឹកខាងលើ ក្លាយទៅជាព្រៃលិចទឹកវិញនោះ នៅក្នុងរយៈពេល ១៥ ឆ្នាំខាងមុខសង្កាត់ស្ទាចមានជ័យមានគំរោងនឹងដាំដើមកោងកាងឡើងវិញ នៅលើផ្ទៃដីចំនួន ០ហ.ត ។

- ដើម្បីធានាបាននូវនិរន្តរភាពរវាងមនុស្ស និងភាវរស់ដែលរស់នៅក្នុងទឹកឱ្យបានគង់វង្ស ។

**តារាងតម្រូវការប្រើប្រាស់ដីអនាគត**

| **ការប្រើប្រាស់ដី** | **ក្រឡាផ្ទៃឆ្នាំនេះ**( ហ.ត) | **ក្រឡាផ្ទៃ១៥ឆ្នាំ**( ហ.ត) | **បំរែបំរួល**( ហ.ត) |
|---|---|---|---|
| ដីភូមិ | ៤០១ | ៧២២ | ៣២១( ហ.ត) |
| ដីវាលកប់ខ្មោច | ១ | ០ | ០ |
| ដីស្រោចស្រព | ០ | ០ | ០ |
| ដីវាលស្រែ | ០ | ១៨ | ១៨( ហ.ត) |
| ដីចំការដំណាំឈើហូបផ្លែ | ៣៧៣ | ១០៩១ | ៧១៨( ហ.ត) |
| ដីព្រៃលិចទឹក | ០ | ០ | ០ |
| ដីវាលស្មៅ | ៨០១ | ៨៩៥ | ៩៤( ហ.ត) |

## ៣.២ ការបែងចែកដីតាមតំរូវការប្រើប្រាស់

### ៣.២.១ ការវិភាគអន្តរអំពើ

ការគ្រប់គ្រង និងបែងចែកសំរាប់ការប្រើប្រាស់ ជាកត្តាដែលធ្វើឱ្យមានការផ្តល់នូវផលប្រយោជន៍ និងមាននិរន្តភាពហើយនឹងមានការប៉ះពាល់ទៅលើផ្នែកមួយចំនួនដូចជា សេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន ដែលក្នុងនោះមានដូចជា :

-ការប្រែប្រួលពីដីវាលស្មៅទៅជាដីស្រែសំរាប់ការបង្កបង្កើនផលនេះជាការពង្រីកលើវិស័យកសិកម្មវាជាកត្តាអំណោយផលដល់ការបង្កើននូវផលិតផល ក៏ដូចជាសេដ្ឋកិច្ចក្នុងមូលដ្ឋាននៅក្នុងបរិបទការប្រែប្រួលប្រភេទដីប្រសិនបើវាលស្មៅដែលជាដីស្រែដែលត្រូវបោះបង់ចោលនោះវាជាមោទនភាពសំរាប់ការពង្រីកលើការងារធ្វើស្រែតែក្នុងករណីវាលស្មៅមានពាក់ព័ន្ធ និងនាទីព្រៃលិចទឹកនោះនិងធ្វើឱ្យមានការប៉ះពាល់ដល់ធនធានធម្មជាតិ ។

-ចំពោះការប្រែប្រួលពីដីស្រែស្រោចស្រព គឺជាការប៉ះពាល់ការបង្កបង្កើនផលក្នុងករណីនេះមិនអាចជៀសវាងបានឡើយ ប៉ុន្តែយើងត្រូវចាប់អារម្មណ៏ទៅលើការជំរុញឱ្យមានការបង្កើននូវផលដំណាំឬសួនដំណាំក្នុងភូមិដ្ឋានដើម្បីបង្កើនប្រាក់ចំណូលតាមគ្រួសាររបស់ប្រជាជនវិញ ។

-ការអភិវឌ្ឍន៍ហេដ្ឋាសម្ព័ន្ធនៅក្នុងមូលដ្ឋានសង្កាត់ គឺជាកត្តាផ្តល់ផលប្រយោជន៍ដល់ប្រជាជននៅក្នុងមូលដ្ឋានដែលក្នុងនោះមានដូចជា:

- ការសាងសង់ផ្លូវគឺជាការសំរួលដល់ការធ្វើដំណើរ និងចរាចរគ្រប់ប្រភេទ ហើយនឹងចូលរួមក្នុងការកាត់បន្ថយការចំណាយទៅលើការងារដឹកជញ្ជូនការអភិវឌ្ឍន៍នេះថ្វីត្បិតតែមានការដោះស្រាយ និងហេតុប៉ះពាល់ខ្លះៗក៏ដោយប៉ុន្តែអាច ផ្តល់នូវផលប្រយោជន៍ដល់ប្រជាជនប្រើប្រាស់ ។

-ដោយឡែកចំពោះការពង្រីកវិស័យអប់រំដោយផ្តោតទៅលើការពង្រីកអាគារសិក្សា និង សាលាគឺជាការចាំបាច់បំផុតសំរាប់បង្កើនធនធានមនុស្សនៅក្នុងមូលដ្ឋាន បច្ចុប្បន្នទៅបីសង្កាត់មានការខ្វះខាតដីសំរាប់បង្កើតសាលាថ្មីសំរាប់ថ្នាក់បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ប៉ុន្តែជាអាទិភាពនៅតាមសាលាចាស់នៅមានដីដែលអាចសាងសង់អាគារសិក្សាបន្ថែមបាន រីឯសាលាមត្តេយ្យដោយមើលឃើញថាការលំបាកសំរាប់កុមារដែលគ្មានលទ្ធភាពក្នុងការសិក្សានៅទីកន្លែងឆ្ងាយ គឺជាអាទិភាពសង្កាត់ សង្កាត់ត្រូវព្យាយាមរកដំណោះស្រាយឱ្យខាងតែបាននៅតាមបណ្តាភូមិគោលដៅព្រោះវាមានសារៈសំខាន់និងជាមូលដ្ឋានគ្រឹះនៃការបណ្តុះបណ្តាល និងការបំពាក់បំប៉នចំណេះដឹងដល់អក្ខរជនក្នុងមូលដ្ឋាន ។

### ៣.២.២. ផែនទីប្រើប្រាស់ដីពេលអនាគត




*រូបទី ៤ : ផែនទីប្រើប្រាស់ដីអនាគត*

### ៣.២.៣ ការបរិយាយការប្រើប្រាស់តាមត្បាលដី

ការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្មាច់មានជ័យ ត្រូវបានបែងចែកទៅតាមគោលការណ៍មួយចំនួន ដែលមានលក្ខណៈជាសត្យានុម័ត ហើយបានអនុលោមទៅតាមមុខងារដូចខាងក្រោម :

ការប្រើប្រាស់ដីសំរាប់លំនៅដ្ឋានដីភូមិ គឺជាដីដែលផ្តល់នូវសក្តានុពលទៅលើការសាងសង់លំនៅដ្ឋាន ដោយមានការដាំដំណាំរួមផ្សំដូចជា ដូង ខ្នុរ ស្វាយ ទៀប ចេក ។ល។ ជាមួយគ្នានោះដែរ ប្រភេទដីលំនៅដ្ឋានអាចមានដីស្រែដែលមានលក្ខណៈជាថ្នាលសំណាប ឬជាដីសំរាប់ដាំដំណាំរយៈពេលខ្លី ដូចជាត្រឡាច ននោង អំពៅ ដំឡូង ស្ពៃ ត្រកួន និងដំណាំប្រគប់ប្រភេទផ្សេងៗទៀត។

ការប្រែប្រួលក៏ដូចជាការកើនឡើងនៃប្រភេទដីស្រែនេះ ការប្រើប្រាស់ដីសំរាប់ដីស្រែនៅក្នុងសង្កាត់ស្មាច់មានជ័យ ត្រូវបានធ្វើការចាត់ជាប្រភេទធ្វើស្រែវស្សា ពង្រីកទៅលើវាលស្មៅដែលជាវាលស្រែ ដែលបានបោះបង់ចោលពីមុនមកនោះ ត្រូវបានធ្វើការរៀបចំកែលំអឡើងវិញទៅតាមលក្ខណៈបច្ចេកទេស កសិកម្មដំណាំស្រូវដល់ប្រជាជន ដើម្បីផ្តល់ឱកាសដល់

ពួកគាត់ឱ្យចូលរួមក្នុងការបង្កើននូវទិន្នផលនៅក្នុងមូលដ្ឋាន ផ្អែកទៅតាមស្ថានភាពដីវាលស្មៅ បច្ចុប្បន្នមានសណ្ឋានជាប់នឹងដីនាទីព្រៃលិចទឹក ប៉ុន្តែចំពោះដីប្រភេទនេះ យើងត្រូវធ្វើការផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ ដើម្បីចៀសវាងការវាតដីចូលក្នុងដីនាទីព្រៃលិចទឹកពុំមានព្រំប្រទល់ច្បាស់លាស់នៅឡើយ សូមបញ្ជាក់ផងដែរថាចំពោះផែនការប្រែដីវាលស្មៅឱ្យទៅជាដីស្រែ គឺសង្កាត់ពុំមានគោលការណ៍យកដីវាលស្មៅដែលស្ថិតនៅក្នុងដីនាទីព្រៃលិចទឹក មកធ្វើការអភិវឌ្ឍន៍ឡើយ ។

- ការប្រើប្រាស់ដីសំរាប់នាទីព្រៃលិចទឹក (ដីសាធារណៈរបស់រដ្ឋ) គឺត្រូវទាមទារឱ្យការថែរក្សាឱ្យបានគង់វង្ស ដូច្នេះសង្កាត់មានគោលបំណងធ្វើការរៀបចំនូវផែនការ ការពារថែរក្សា អភិរក្ស និងអភិវឌ្ឍន៍ទៅលើធនធានទាំងនេះ ដើម្បីផ្តល់នូវផលប្រយោជន៍ក្នុងការបង្កើនប្រាក់ចំណូល សំរាប់ប្រជាជនតាមរយៈការប្រើប្រាស់ប្រកបដោយនិរន្តរភាព ។

- នៅក្នុងការប្រែប្រួលពីដីវាលស្មៅ ទៅជាដីដែលមានព្រៃលិចទឹកនោះ គឺជាអាទិភាពដោយសារដីប្រភេទវាលស្មៅដែលស្ថិតក្នុងនាទីព្រៃលិចទឹក គឺជាដីព្រៃលិចទឹកដែលបានឆេះកន្លងមកក្លាយជាវាលស្មៅ ដូចជាគោលការណ៍ត្រូវការពារថែរក្សាទុកឱ្យព្រៃលិចទឹកដុះឡើងវិញ ដើម្បីធានាធនធានក្នុងតំបន់ ។

- ចំពោះប្រជាជនដែលរស់នៅលើដីសាធារណៈរបស់រដ្ឋ (ដីមាត់ព្រែក) បច្ចុប្បន្នអ្នកដែលរស់នៅចាស់មានការ លំបាកក្នុងការផ្លាស់ប្តូរ ប៉ុន្តែជាគោលការណ៍សង្កាត់ធ្វើការហាមឃាត់ការកសាងលំនៅដ្ឋានថ្មី ។

- ការប្រើប្រាស់ដីសំរាប់ការកសាងផ្លូវថ្នល់ផ្លូវថ្នល់ក៏មានបញ្ហាខ្លះដែរ ប៉ុន្តែអាចដោះស្រាយព្រោះថាផ្លូវដែលកើតឡើងគឺជាការផ្តើមចេញពីប្រជាជនផ្ទាល់ ដែលជាអ្នកធ្វើឱ្យកើតមានផ្លូវជាដំបូង ហើយសង្កាត់ក៏លើកគំរោងអភិវឌ្ឍន៍ទៅតាមការស្នើឡើងពីសំណាក់ប្រជាជន។ បច្ចុប្បន្នការអភិវឌ្ឍន៍ទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងសង្កាត់គឺអនុវត្តន៍ទៅលើផ្លូវចាស់ដែលមានស្រាប់ ដូច្នេះដំណោះស្រាយអាចដោះស្រាយបាន ។

### ៣.២.៣.១ ដីលំនៅដ្ឋាន (បញ្ញាតិគោលការណ៍នៃការប្រើប្រាស់ដី)

តាមស្ថានភាពជាក់ស្តែងដែលបានគ្រោងទៅលើចំនួនគ្រួសារដែលគ្មានដីបច្ចុប្បន្នចំនួន ៥៤ គ្រួសារ និងអត្រាកំណើនរបស់ប្រជាពលរដ្ឋចំនួន ១៥៥៣ គ្រួសារ សំរាប់រយៈពេល ១៤ ឆ្នាំខាងមុខ ប៉ុន្តែនៅក្នុងការគិតគូរទៅលើការកំណត់ផ្ទៃដីលំនៅដ្ឋានក្នុងមួយគ្រួសារ ១០,២០ ហត នោះសង្កាត់អាចមានលទ្ធភាពបំពេញតំរូវការដី ៣២១ ហត តាមចំនួនគ្រួសារដែលគ្មានដីបច្ចុប្បន្នចំនួន ៥៤ គ្រួសារ និងតាមអត្រាកំណើនប្រជាពលរដ្ឋចំនួន ១៥៥៣ គ្រួសារ ហើយត្រូវបានកំណត់ និងអភិវឌ្ឍន៍ទៅតាមតំបន់គោលដៅដូចខាងក្រោមៈ

**ទីតាំងដីមានលេខកូដ F១២០០-០៣**

ក្នុងការអភិវឌ្ឍន៍នៅលើទីតាំងដីមានលេខកូដ F១២០០-០៣ សង្កាត់បានធ្វើការគិតគូរដោយផ្អែកទៅលើការរីកដុះដាលនៃដីសំរាប់សង់លំនៅដ្ឋានតាមម្ខាងផ្លូវសេរីការ និងអមសងខាងផ្លូវជាតិលេខ ៤៨ មានទំហំ ៧៩,៥៨ ហត ដោយគ្រោងសំរាប់ប្រជាពលរដ្ឋចំនួន ៤៩៨ គ្រួសារសំរាប់អភិវឌ្ឍន៍នៅ ៥ឆ្នាំទី ១ (២០០៩-២០១២)។ ប៉ុន្តែបើតាមការកំណត់ទំហំដីខាងលើ ០,២០ ហត ក្នុងមួយគ្រួសារនោះ ទំហំដី ៧៩,៥៨ ហតនេះមានលទ្ធភាពអាចទទួលបានតែចំនួន ៣៩៨ គ្រួសារប៉ុណ្ណោះ នៅសល់ ១០០គ្រួសារស្មើនឹងផ្ទៃដីចំនួន ២០ ហត ត្រូវយកទៅអភិវឌ្ឍន៍ទៅលើទីតាំងដីមានលេខកូដ F១២០០-០២ បន្ត។

**ទីតាំងដីមានលេខកូដ** F 1200-02

ទីតាំងដីមានលេខកូដ F1200-02 ស្ថិតនៅក្នុងភូមិបឹងឃុនឆាងមានទំហំ ១២៦,៧១ ហត តាមគំរោងត្រូវអភិវឌ្ឍន៍នៅជំហ៊ានទី ២ ឬ ៥ឆ្នាំទី ២ (២០១២-២០១៧)។ បើយោងតាមការគណនាឃើញថាចាប់ពី ២០១២-២០១៧ មានប្រជាពលរដ្ឋកើនឡើងរហូតដល់ ៥៥៥ គ្រួសារដែលតំរូវការសំរាប់សាងសង់លំនៅដ្ឋានមានចំនួន ១១១ ហត ដូច្នេះទំហំដីខាងលើ ១២៦,៧១ ហត មិនអាចមានលទ្ធភាពទទួលប្រជាពលរដ្ឋបានតាមអត្រាកំណើន ៥៥៥ គ្រួសារបានទេ ដោយផ្ទៃដីនេះបានផ្តល់អោយទៅប្រជាជនចំនួន ១០០គ្រួសារ ស្មើនឹង ២០ ហត កាលពី ៥ឆ្នាំទី ១។ ដូច្នេះ ផ្ទៃដីដែលនៅសល់ពីការផ្តល់ជូនប្រជាពលរដ្ឋនៅ ៥ឆ្នាំទី ១ មានតែចំនួន ១០៦,៧១ ហត ស្មើនឹង ៥៣៣ គ្រួសារប៉ុណ្ណោះ ហើយចំនួននេះដកនឹងអត្រាកំណើនប្រជាជនឆ្នាំ ២០១២-២០១៧ មាន ៥៥៥គ្រួសារស្មើនឹងផ្ទៃដី ៤,៤ ហត ដែលត្រូវយកទៅអភិវឌ្ឍទៅលើទីតាំងដី F1200-01 ។

**ទីតាំងដីមានលេខកូដ** F 1200-01

ដីមានលេខកូដ F1200-01 ស្ថិតនៅម្តុំស្តូបស្ថិតនៅក្នុងភូមិបឹងឃុនឆាង និងភូមិស្នាច់មានជ័យមានទំហំ ១១៥,១៥ ហត ដកនឹង ៤,៤ ហត ស្មើនឹង ២២ គ្រួសារដែលបានយកមកដាក់កាលពី ៥ ឆ្នាំទី ២ ផ្ទៃដីនៅសល់មាន ១១០,៧៥ ហត សំរាបប្រជាជន ៥៥៤ គ្រួសារ ត្រូវធ្វើការអភិវឌ្ឍន៍នៅក្នុង ៥ឆ្នាំទី ៣ (២០១៧-២០២២)។

នៅក្នុងការប្រែប្រួលដីលំនៅដ្ឋានតាមរយៈការរីកដុះដាលនៃគ្រួសារ របស់ប្រជាជនដោយការបែងកើ្តទុកអោយកូន និងការលក់ដោះដូរជាប្រាក់លើដីដែលមានការកាន់កាប់ស្រាប់ប៉ុណ្ណោះ ព្រោះសង្កាត់ពុំមានដីសម្បទានសង្គមកិច្ចសំរាប់ធ្វើការបែងចែកជូនប្រជាពលរដ្ឋសំរាប់សាងសង់លំនៅដ្ឋានឡើយ។ រីឯស្ថានភាពនៃការដុះដាលសំរាប់ប្រភេទដីលំនៅដ្ឋាននេះគឺភាគច្រើនរីកតាមបណ្តោយផ្លូវដែលមានស្រាប់ និងមានប្រភពទឹកអាចប្រើប្រាស់បាន (ទឹកអណ្តូងលូ)។ ការបង្កើតលំនៅដ្ឋានថ្មីតូច ឬធំទៅតាមស្ថានភាពដីដែលឪពុកម្តាយចែកអោយ ឬលទ្ធភាពនៃការទិញប៉ុណ្ណោះ ។

**បញ្ញាតិនៃការប្រើប្រាស់ដីសំរាប់សង់លំនៅដ្ឋានថ្មីគឺ :**

នៅក្នុងការពង្រីកដីសំរាប់សង់លំនៅដ្ឋាន សង្កាត់មានគោលការណ៏រៀបចំដីលំនៅដ្ឋានដែលបានកំណត់អោយមានសណ្តាប់ធ្នាប់សាធារណៈល្អ ហើយត្រូវអនុវត្តដូចខាងក្រោម :

- រាល់ដីលំនៅដ្ឋានដែលរៀបចំថ្មីត្រូវបានកំណត់ទុកចំណីផ្លូវស្របតាមច្បាប់កំណត់
- ចំពោះដីលំនៅដ្ឋានរៀបចំថ្មីនៅតាមព្រែកអូរ ...ត្រូវអនុវត្តដោយទុកចំណីព្រែក អូរ..តាមច្បាប់កំណត់ ។
- ការសាងសង់លំនៅដ្ឋានត្រូវអនុវត្តទៅតាមច្បាប់អនុញ្ញាតិ
- មិនត្រូវសាងសង់លំនៅដ្ឋានលើដីសាធារណៈរបស់រដ្ឋជាដាច់ខាត

- រាប់ពីលំនៅដ្ឋានដែលកើតថ្មីត្រូវមានការកំណត់ព្រំប្រទល់អោយបានច្បាស់លាស់ដោយមានការឯកភាពគ្មានវាងភាគីពាក់ព័ន្ធ ហើយត្រូវបានបោះបង្គោលស៊ីម៉ង់ត៍ទុកចំណាំ ។
- ជំរុញ និងផ្សព្វផ្សាយអោយមានការចូលរួមបង្កើននូវផលិតផលតាមរយៈការរៀបចំជាសួនដំណាំនៅក្នុងដីលំនៅដ្ឋានដូចជា សួនបន្លែ និងដំណាំរួមផ្សំរយៈពេលខ្លី និងវែង ដែលជាកត្តាជួយក្នុងភូមិមានសភាពបៃតងជានិច្ច ដោយមានលទ្ធភាពបង្កើនប្រាក់ចំណូលក្នុងគ្រួសារលើសកម្មភាពនេះ ។

### ៣.២.៣.២ ដីស្រែវស្សា និងស្រែប្រាំង

- ការប្រើប្រាស់ដីស្រែនៅក្នុងសង្កាត់ស្ទាច់មានជ័យត្រូវបានធ្វើការចាត់ថ្នាក់ជាដីមួយប្រភេទ គឺការធ្វើស្រែវស្សាដែលពឹងផ្អែកទៅលើទឹកភ្លៀងដែលក្នុងនោះសង្កាត់ពុំមានទំនប់ ឬ ប្រឡាយទឹកសាបដើម្បីយកមកស្រោចស្រពស្រូវវស្សាបានទេ ហេតុដូចនេះហើយទើបការធ្វើស្រូវវស្សារបស់ប្រជាជនមានតែមួយដងគត់គឺនៅរដូវភ្លៀង ។

### គោលការណ៍នៃការប្រើប្រាស់ដីកសិកម្ម

នៅក្នុងដំណើរការអភិវឌ្ឍន៍សំរាប់ពេលអនាគត សង្កាត់មានគោលការណ៏ក្នុងការរៀបចំទៅការបង្កើនផលិតកម្មកសិកម្មដំណាំស្រូវដែលត្រូវអនុវត្តនូវយុទ្ធសាស្ត្រមួយចំនួនដែលអាចជួយដល់ការបង្កើនផលិតផលកសិកម្មគឺ :

- លើកកំពស់ការប្រើប្រាស់ដីធម្មជាតិ ដីកំប៉ុស្តិ៍
- កាត់បន្ថយការប្រើប្រាស់ជីគីមី
- កាត់បន្ថយការប្រើប្រាស់ថ្នាំពុល និងជំរុញការអនុវត្តកម្មវិធី IPM
- បង្កើនការដាំដុះដំណាំរយៈពេលខ្លីទៅលើដីស្រែដែលមានលទ្ធភាព ដើម្បីអោយការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាព និងមានតម្លាភាពសង្កាត់បានកំណត់ដូចខាងក្រោមៈ
- ហាមដាច់ខាតការពង្រីកដីលើដីសាធារណៈរបស់រដ្ឋ
- ហាមដាច់ខាតការវាតដីស្រែចូលដីប្រឡាយ
- ហាមឃាតដាច់ខាតការកាប់រានចូលដីព្រៃកោងកាងដើម្បីយកដីធ្វើស្រែ

### ៣.២.៣.៣ ការប្រើប្រាស់ទឹក និងប្រព័ន្ធស្រោចស្រព

ការប្រើប្រាស់ដីផ្ទៃទឹកនៅក្នុងសង្កាត់គឺជាកត្តាចំបងសំរាប់ប្រជាជននៅក្នុងមូលដ្ឋាន ដើម្បីបំរើផលប្រយោជន៍និងការប្រើប្រាស់ទូទៅផ្អែកតាមធនធានទឹកដែលមាននៅក្នុងសង្កាត់លទ្ធភាពក្នុងការដកយកមកប្រើប្រាស់តាមប្រភេទទឹកស្ទឹង និង បឹងតែអកុសលសង្កាត់ស្ទាច់មានជ័យពុំមានទំនប់ការពារទឹកសាប និងប្រឡាយដោយឡែកចំពោះប្រព័ន្ធប្រឡាយរំដោះទឹកបច្ចុប្បន្នពុំអាចមានលទ្ធភាពក្នុងការប្រើប្រាស់គ្រប់គ្រងបានឡើយ ( ប្រឡាយរាក់) ។

## ប្រព័ន្ធស្រោចស្រព

ការប្រែប្រួលប្រព័ន្ធប្រឡាយរំដោះទឹក ឬដីប្រឡាយចាស់មកជាប្រឡាយថ្មីនោះជាបញ្ហាចោទមួយព្រោះថាមានការលំបាកសំរាប់ការដោះស្រាយនៅបញ្ហាប្រឈមដោយបច្ចុប្បន្នមានបញ្ហាមួយចំនួន និងត្រូវកើតមាន

ឡើងក្នុងពេលប្រឡាយចាប់ផ្តើមដំណើរការសាងសង់ និង ស្តារដូចជាការរំលោភយកដីប្រឡាយរំដោះទឹក រីឯបញ្ហាមួយផ្សេងទៀតបើក្នុងករណីមានការសាងសង់ប្រឡាយរំដោះទឹកថ្មីបញ្ហា និងកើតឡើងដោយសារការមិនយល់ពីសារៈប្រយោជន៍ក្នុងការប្រើប្រាស់ប្រឡាយរំដោះទឹកភ្លៀង ដូច្នេះបញ្ហានៃការប៉ះពាល់ប្រឡាយរំដោះទឹកធ្វើអោយសង្កាត់ប្រឈមមុខក្នុងការដោះស្រាយ ។

### ទីតាំងដីប្រឡាយរំដោះទឹកលេខកូដ FDN 56-01

ក្នុងការរៀបចំប្រឡាយរំដោះទឹក ដែលមានលេខកូដក្នុងផែនទីលេខ FDN56-01 មានប្រវែង ២៨៩,៥២ម ស្ថិតនៅក្នុងភូមិស្នាច់មានជ័យ ហើយដែលត្រូវអនុវត្តន៏ក្នុងឆ្នាំទី ១គឺចាប់ពីឆ្នាំ ២០០៩-២០១២ ។

នៅក្នុងការស្តារប្រឡាយរំដោះទឹកដែលមានលេខកូដក្នុងផែនទី FDN56-02 មានប្រវែង ១៣២,៥០ ម ដែលស្ថិតនៅក្នុងភូមិបឹងឃុនឆាងគឺចាប់ពីមុខសាលារៀនបឹងឃុនឆាងរហូតជិតដល់ផ្លូវសេរីកា ហើយផ្លូវត្រូវអនុវត្តក្នុងឆ្នាំទី ២ គឺចាប់ពីឆ្នាំ ២០១៣-២០១៧ ។

### បញ្ញាតិ និងគោលការណ៍នៃការកសាង និងស្តារប្រឡាយរំដោះទឹក

- នៅក្នុងលក្ខខណ្ឌនៃការសាងសង់ និងស្តារប្រឡាយរំដោះទឹក ត្រូវមានការកំណត់អោយបានច្បាស់ទៅលើការដោះស្រាយបញ្ហាទើបដំណើរការប្រព្រឹត្តទៅទទួលជោគជ័យ ។
- រៀបចំគណៈកម្មការចុះដោះស្រាយអនុវត្ត និងថែទាំ
- ការសាងសង់ប្រឡាយរំដោះទឹកថ្មី ត្រូវអនុវត្តដោយទុកចំណីប្រឡាយអោយសមស្របតាមស្ថានភាជាក់ស្តែង ។
- ការស្តារប្រឡាយរំដោះទឹកចាស់ត្រូវអនុវត្តសមស្របទៅតាមទំហំប្រឡាយរំដោះទឹកចាស់ ។
- ត្រូវធ្វើការដោះស្រាយអោយបានរួចរាល់នូវការរំលោភយកដីប្រឡាយរំដោះទឹកចាស់ និងកែសំរួលទៅតាមស្ថានភាពជាក់ស្តែង និងសមស្របតាមគោលការណ៍ច្បាប់ ។

### ការប្រើប្រាស់ទឹក

ដោយឡែកចំពោះប្រជាជនដែលរស់នៅលើផ្ទៃទឹកដងព្រែកកោះប៉ោ ត្រូវបានប្រើប្រាស់ធនធានដែលមាននៅក្នុងមូលដ្ឋានដូចជាការប្រកបរបរនេសាទ នៅលើដែននេសាទសមុទ្រដោយមានការការពារ និងថែរក្សា ។ ប៉ុន្តែកត្តានេះមានការពាក់ព័ន្ធទៅនឹងផលប៉ះពាល់បរិស្ថាន ដូច្នេះនៅពេលអនាគតប្រសិនបើរាជរដ្ឋាភិបាលមានគោលការណ៍អោយ

ប្រជាជនដែលរស់នៅតាមដងព្រែកោះប៉ោត្រូវផ្លាស់ប្តូរលំនៅដ្ឋានមករស់នៅផ្នែកខាងលើគោកវិញ  សង្កាត់នឹងធ្វើការចូលរួមរកដំណោះស្រាយអោយសមស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**៣.២.៣.៤ ការសាងសង់ដាក់លូឆ្លងកាត់ផ្លូវ**

នៅក្នុងការអភិវឌ្ឍន៍ទៅហេដ្ឋារចនាសម្ព័ន្ធសង្កាត់  ក៏បានចាប់អារម្មណ៍ទៅលើការសាងសង់លូឆ្លងកាត់ផ្លូវដែលក្នុងនោះត្រូវបានគ្រោងសាងសង់ដាក់លូឆ្លងកាត់ផ្លូវក្នុងភូមិ ១ ភូមិ ៣ ភូមិស្ទាច់មានជ័យ មានចំនួន៤កន្លែង ដែលមាននៅក្នុងនោះត្រូវបានដំណើរការទៅតាមទីតាំង និងស្ថានភាពដូចខាងក្រោម

**ទីតាំងនៃការសាងសង់លូឆ្លងកាត់ផ្លូវ**

ការសាងសង់លូឆ្លងកាត់ផ្លូវថ្នល់ក្នុងសង្កាត់ស្ទាច់មានជ័យ គឺជាការចាំបាច់ ហើយសង្កាត់ធ្វើការកំណត់លើការសាងសង់លូក្នុងភូមិ ១ មានចំនួន ១ កន្លែង ភូមិ ៣ មាន ១ កន្លែង ភូមិស្ទាច់មានជ័យមាន ០២ កន្លែង។

បញ្ញាតិ និងគោលការណ៍នៃការសាងសង់លូឆ្លងកាត់ផ្លូវ

- ការសាងសង់លូឆ្លងកាត់ផ្លូវត្រួតពិនិត្យទៅលើតាមស្ថានភាពជាក់ស្តែង
- ការជ្រើសរើសទីតាំងត្រូវអនុលោមទៅតាមស្ថានភាពកន្លែងដែលសមស្រប
- ការសាងសង់ត្រូវអនុវត្តទៅតាមបច្ចេកទេសអោយបានត្រឹមត្រូវ
- នៅក្នុងស្ថានភាពនៃការសាងសង់លូឆ្លងកាត់ផ្លូវត្រូវធ្វើការសិក្សាស្រាវជ្រាវ និងធ្វើការវាយតំលៃដោយស៊ីជំរៅ។

**៣.២.៣.៥ ការប្រើប្រាស់ផ្លូវថ្នល់**

ការប្រើប្រាស់ដីសំរាប់ការកសាងផ្លូវថ្នល់ ក៏មានបញ្ហាខ្លះដែរ ប៉ុន្តែអាចដោះស្រាយបានព្រោះថាផ្លូវដែលកើតឡើងគឺជាការផ្តើមចេញពីប្រជាពលរដ្ឋផ្ទាល់ដែលជាអ្នកធ្វើអោយកើតផ្លូវជាដំបូង ហើយសង្កាត់ក៏លើកគំរោងអភិវឌ្ឍន៍ទៅតាមការស្នើឡើងពីសំណាក់ប្រជាជន។  បច្ចុប្បន្នការអភិវឌ្ឍន៍ទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងគឺអនុវត្តទៅលើផ្លូវចាស់ដែលមានស្រាប់ ដូច្នេះដំណោះស្រាយអាចដោះស្រាយបាន។

**ទីតាំងផ្លូវចាក់កៅស៊ូលើផ្លូវគ្រាលគ្រួសក្រហមចាស់**ដែលមានស្រាប់នៅក្នុងសង្កាត់ស្ទាច់មានជ័យមានចំនួន ០៤ ខ្សែ ក្នុងនោះមានចំនួន ០២ ខ្សែជាផ្លូវអន្តរសង្កាត់គឺរវាងសង្កាត់ស្ទាច់មានជ័យជាមួយសង្កាត់ស្ទឹងវែងខ្សែទី ១ ស្ថិតនៅលើផ្លូវសេរីការចាប់ពីកែងផ្លូវមកពីតំបន់ប្រតិបត្តិការណ៍សិកខេត្តកោះកុងរហូតដល់ផ្លូវកែងព្រែកស្វាយមានប្រវែង ២៦៥៦ ម មានលេខកូដ FRD 2-03 ចាប់ផ្តើមអនុវត្តនៅ ៥ឆ្នាំទី ១ (២០០៩-២០១២) ខ្សែទី ២ ស្ថិតនៅលើផ្លូវព្រែកស្វាយចាប់ពីមុខសាលាក្រុងខេមរភូមិន្ទរហូតដល់ផ្លូវកែងសេរីការមានមានប្រវែង ១,៧១០ម មានលេខកូដ FRD 2-02 និង ០១ ខ្សែទៀតស្ថិតសង្កាត់ស្ទាច់មានជ័យចាប់ពីផ្លូវកែងលេខ ៤៨ កាត់តាមមុខវត្តទេពនិមិត្តជលសារ (ហៅវត្តថ្មី) រហូតមកផ្លូវកែងទៅសាលាក្រុងខេមរភូមិន្ទមានប្រវែង ១,០១៦ ម និងមានលេខកូដ FRD 2-01 ផ្លូវទាំងពីរខ្សែនេះ និងត្រូវអភិវឌ្ឍន៍ទៅ ៥ឆ្នាំទី ២ (២០១២-២០១៧) ដោយឡែកផ្លូវដែលមានលេខកូដ FRD 2-04

ចាប់ពីមុខតំបន់ប្រតិបត្តិសិកខេត្តកោះកុងរហូតដល់កែងផ្លូវលេខ ៤៨ (ជិតអូរស្រីស្រណោះ) មានប្រវែង ២៦៧២ ម និង ត្រូវធ្វើការអភិវឌ្ឍន៍ទី ៥ ឆ្នាំទី ៣(២០១៧-២០២២) ខាងមុខ។

**ទីតាំងផ្លូវចាក់បេតុងលើផ្លូវក្រួសក្រហម ដែលមានលេខកូដ** FRD9-01/ FRD9-02/ FRD9-03/ FRD9-03/ FRD9-04/ FRD9-05/ FRD9-06/ FRD9-07/ FRD9-08/ FRD9-09, FRD9-10, FRD9-11, FRD9-12, FRD9-13, FRD9-14, FRD9-15, FRD9-16, FRD9-17, FRD9-18, FRD9-19, FRD9-20, FRD9-21, FRD9-22, FRD9-23 និង FRD9-24

ការសាងសង់ផ្លូវបេតុងចាប់ពីឆ្នាំ ២០០៩-២០២២ មានគំរោងសាងសង់ចំនួន ២៤ ខ្សែ ដែលស្ថិតនៅក្នុងសង្កាត់ស្មាច់មានជ័យទាំងអស់ខ្សែទី ១ មានលេខកូដ FRD៩-០១ មានប្រវែង ៤៥៧ ម ចាប់ពីមុខវត្តទេពនិមិត្តជលសារ (ហៅវត្តថ្មី) រហូតដល់ផ្លូវកែងសពយុវជន, ខ្សែទី ២ មានលេខកូដ FRD៩-០២ ចាប់ពីផ្លូវកែង Karaoke ដូនទាវរហូតដល់ផ្លូវកែងមុខមន្ទីរព័ត៌មានខេត្តមានប្រវែង ៦៨៤ ម ខ្សែទី ៣ មានលេខកូដ FRD៩-០៣ ចាប់ពីផ្លូវកែងមុខផ្ទះសំណាក់ប៊ុន ថាំរហូតដល់ផ្លូវកែងសពយុទ្ធជនមានប្រវែង ៤០៥ម ខ្សែទី ៤ មានលេខកូដ FRD៩-០៤ នៅជាប់រោងកុនចាស់មានប្រវែង ១៤៧ ម ខ្សែទី ៤ មានលេខកូដ FRD៩-០៥ នៅជិតផ្ទះសំណាក់តាប្រូមានប្រវែង ៧៤ ម ខ្សែទី ៦ មានលេខកូដ FRD៩-០៦ នៅខាងក្រោយសណ្ឋាគារនគររាជមានប្រវែង ៧៦ ម ខ្សែទី ៧ នៅខាងជើងជាប់ដីអធិការនគរបាលស្រុកចាប់មានលេខកូដ FRD៩-០៧ មានប្រវែង ៥៣ ម ខ្សែទី ៨ មានលេខកូដ FRD៩-០៨ ចាប់ពីកែងមុខមន្ទីរសង្គមកិច្ចអតីតយុទ្ធជនរហូតដល់ផ្លូវកែងធនាគារខេត្តមានប្រវែង ៥៨៦ម ខ្សែទី ៩ មានលេខកូដ FRD៩-០៩ ចាប់ពីមុខ PM ខេត្តរហូតដល់ជិតស្រែបង្កាលោកយន្ត មីន មានប្រវែង ១១៥២ម និងខ្សែទី ១០ ផ្លូវមានលេខកូដ FRD-១១ ចាប់ពីផ្លូវកែងក្រោយ PM ខេត្តរហូតដល់ផ្លូវកែងក្រោយផ្ទះលោក កាន់ ណាំ មានប្រវែង ៦៩៣ម ផ្លូវទាំង ១០ ខ្សែនេះតាមគំរោងត្រូវអភិវឌ្ឍន៏នៅក្នុង៥ឆ្នាំទី ១ (២០០៩-២០១២)។ ផ្លូវមានលេខកូដ FRD៩-១០ ចាប់ពីផ្លូវកែងមុខផ្ទះខ្មោចតា លិ ខណៈ រហូតដល់ផ្លូវកែងស្តូប (ទៅខាងជើង) មានប្រវែង ៦៩៥ ម ផ្លូវមានលេខកូដ FRD៩-១២ ចាប់ពីផ្លូវកែងមុខផ្ទះលោកសិរិតាក់តើ កាត់តាមខាងលិចជាប់គណបក្សហ៊្វុនស៊ីប៉ិចរហូតដល់បឹងកូឡូរីសត OASIS មានប្រវែង ១០៧៥ម ផ្លូវមានលេខកូដ FRD៩-១៣ ចាប់ពីផ្លូវកែងមុខផ្ទះលោក ឯក ម៉ឹង រហូតដល់មុខផ្ទះលោក ឆវី ភូថងមានប្រវែង ៣៤២ម ផ្លូវមានលេខកូដ FRD៩-១៤, FRD៩-១៥, FRD៩-១៦ និង FRD៩-១៧ ស្ថិតនៅម្តុំសាលាបឋមសិក្សាស្មាច់មានជ័យមានប្រវែង ៧២៨ម,៧២០ម,៧០៩ម និង ៧០៨ម តាមគំរោងត្រូវអភិវឌ្ឍន៏នៅ ៥ ឆ្នាំទី ២ (២០១២-២០១៧) ផ្លូវមានលេខកូដ FRD៩-១៨, FRD៩-១៩, FRD៩-២៣, FRD៩-២៤ នៅម្តុំផ្ទះលោក អ៊ុន ប៊ុនថា មេបញ្ជាការយោធាក្រុងខេមរភូមិន្ទមានប្រវែងជាបន្តបន្ទាប់ ៧០៣ម,៨០៨ម,៣០២ម,៣០០ម និងផ្លូវមានលេខកូដ FRD៩-២០, FRD៩-២១ និង FRD៩-២២ ស្ថិតនៅភូមិបឹងយុនឆាង (ក្នុងភូមិថ្មី) មានប្រវែង ១៦២៦ ម, ៣៩៦ម និង ២៥៤ម តាមរយៈគំរោងត្រូវធ្វើការអភិវឌ្ឍន៏នៅក្នុង ៥ ឆ្នាំ ទី ៣ (២០១៧-២០២២)។

**ទីតាំងផ្លូវគ្រួសក្រហមមានលេខកូដ FRD៣-០១, FRD៣-០២, FRD៣-០៣, FRD៣-០៤, FRD៣-០៥ និង FRD៣-០៦**

ការស្ថាបនាផ្លូវក្រាលគ្រួសក្រហមនៅលើផ្លូវដីសមានចំនួន ៦ខ្សែ: ១ខ្សែមានលេខកូដ FRD៣ -០១ ចាប់ពីដីចំការកូនឈើរហូតដល់ផ្លូវ ៤៨ ម មានប្រវែង ៥៣២ម ផ្លូវមានលេខកូដ FRD៣-០២ ស្ថិតនៅម្តុំភោជនី យដ្ឋាន ៤៨ មានប្រវែង ២៥៨ម និងផ្លូវមានលេខកូដ FRD៣-០៤ នៅជាប់វិហាកូរ៉េមានប្រវែង ៤២៥ម តាមគំរោងត្រូវ ធ្វើការអភិវឌ្ឍន៍នៅ ៥ ឆ្នាំទី ២ (២០១២-២០២២) ។ ផ្លូវមានលេខកូដ FRD៣-០៥ ចាប់ពីផ្លូវកែងខាងជើងស្ពានថ្មខាវ៉ាអូខេ ដូនទាវរហូតដល់ចំការកូនឈើ មានប្រវែង ១១១២ ម តាមគំរោងត្រូវអភិវឌ្ឍន៍នៅ ៥ឆ្នាំទី ១ (២០០៩-២០១២) ផ្លូវមានលេខកូដ FRD៣-០៣ និង FRD៣-០៦ ស្ថិតនៅភូមិបឹងឃុនឆាងមានប្រវែង ៩០៥ ម និង ៣៥១ ម តាមគំរោងត្រូវធ្វើការអភិវឌ្ឍន៍នៅ៥ ឆ្នាំទី ៣ (២០១៧-២០២២) ។

**បញ្ញាតិ និងគោលការណ៍នៃការប្រើប្រាស់ផ្លូវថ្នល់**

ការស្ថាបនាផ្លូវត្រូវបានកំណត់ដូចខាងក្រោម :

- ផ្លូវកៅស៊ូទុកទំហំផ្លូវសរុបពី ២០-៤០ម (ពីអក្សរទៅចំណើផ្លូវពី ១០-២០មសងខាង
- ផ្លូវបេតុង និងផ្លូវគ្រួសក្រហមទុកទំហំផ្លូវពី ១០-២០ ម (ពីអ័ក្សទៅចំណើផ្លូវមានពី ៥-១០ ម សងខាងផ្លូវ)
- ការកំណត់លើការប្រើប្រាស់ផ្លូវថ្នល់ត្រូវអនុលោមទៅតាមច្បាប់
- បង្កើតគណៈកម្មការថែទាំផ្លូវថ្នល់ដោយមានការចូលរួមពីប្រជាជនក្នុងមូលដ្ឋាន
- ហាមការដឹកជញ្ជូនលើសទំងន់
- ហាមយកគោ ក្របី ជ្រូក ..ចងលើផ្លូវ
- រៀបចំផ្លាកសញ្ញាចរាចរណ៍តាមបណ្តោយផ្លូវ

**៣.២.៣.៦ ការប្រើប្រាស់ដីសំរាប់វិស័យសិក្សាធិការ**

នៅក្នុងសង្កាត់ស្ទាច់មានជ័យដោយតម្រូវអគារសិក្សាសំរាប់សាលាមត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យត្រូវបានគ្រោងបង្កើតសាលា និងសាងសង់អាគារបន្ថែមដែលក្នុងនោះ

- បង្កើតសាលាមត្តេយ្យចំនួន ៥ អគារស្មើនឹង ២៧ បន្ទប់
- សាលាមត្តេយ្យសម្តេច ជា ស៊ីម ស្ថិតនៅភូមិ ៣ មាន ១អគារស្មើនឹង ៥បន្ទប់សំរាប់ឆ្នាំទី ១
- សាលាមត្តេយ្យទីរួមខេត្តស្ថិតនៅក្នុងភូមិ ១ មាន ១អាគារស្មើនឹង ៥ បន្ទប់សំរាប់ឆ្នាំទី ១
- សាលាមត្តេយ្យស្ទាច់មានជ័យស្ថិតនៅក្នុងភូមិស្ទាច់មានជ័យមាន ១ អគារស្មើនឹង ៥ បន្ទប់សំរាប់ឆ្នាំទី ២ ។
- សាលាមត្តេយ្យបឹង ឃុនឆាង ស្ថិតនៅក្នុងភូមិ បឹង ឃុនឆាងមាន ០១ អគារ ៦ បន្ទប់សំរាប់ឆ្នាំទី ៣ និង សាលាមត្តេយ្យសម្តេច ជា ស៊ីម មាន ១ អគារ ៦ បន្ទប់សំរាប់ឆ្នាំទី ៣

- សាលាបឋមសិក្សាក្នុងបច្ចុប្បន្ននេះរហូតដល់ឆ្នាំ ២០១២ ពុំត្រូវការសាងសង់បន្ថែម
- សាលាបឋមសិក្សាសម្តេច ជា ស៊ីម ស្ថិតនៅក្នុងភូមិ ៣ សាងសង់ ១អគារ ស្មើនឹង ០៧បន្ទប់ សំរាប់ឆ្នាំទី ២។
- សាលាបឋមសិក្សាទីរួមខេត្តស្ថិតនៅក្នុងភូមិ ១ សាងសង់ ២ អគារស្មើនឹង ១១បន្ទប់ សំរាប់ឆ្នាំទី ៣ ។
- សាលាបឋមសិក្សាសម្តេច ជា ស៊ីម ស្ថិតនៅក្នុងភូមិ ៣ សាងសង់សាលា ១ អគារស្មើនឹង ៥ បន្ទប់សំរាប់ឆ្នាំទី ៣។
- សាលាបឋមសិក្សាស្មាច់មានជ័ស្ថិតនៅភូមិស្មាច់មានជ័យសាងសង់ ១អគារស្មើនឹង ០៥ បន្ទប់ សំរាប់ឆ្នាំទី ៣។
- សាលាបឋមសិក្សាបឹងឃុនឆាងស្ថិតនៅភូមិបឹងឃុនឆាង សាងសង់សាលា ១អគារស្មើនឹង ០៥ បន្ទប់សំរាប់ឆ្នាំទី ៣។
- សាលាអនុវិទ្យាល័យសម្តេច ជា ស៊ីមស្ថិតនៅក្នុងភូមិ ៣ សាងសង់សាលា ១ អគារស្មើនឹង ៧ បន្ទប់សំរាប់ឆ្នាំទី ១។
- សាលាអនុវិទ្យាល័យស្ថិតក្នុងវិទ្យាល័យកោះកុងស្ថិតនៅក្នុងភូមិ ១ សាងសង់សាលា ១ អាគារស្មើនឹង ៤ បន្ទប់សំរាប់ឆ្នាំទី ២។
- សាលាអនុវិទ្យាល័យសម្តេច ជា ស៊ីម ស្ថិតនៅភូមិ ៣ សាងសង់ ១ អគារស្មើនឹង ៤ បន្ទប់សំរាប់ឆ្នាំទី ២។
- សាលាអនុវិទ្យាល័យស្ថិតនៅក្នុងវិទ្យាល័យកោះកុងក្នុងភូមិ ១ សាងសង់ ២ អគារស្មើនឹង ១៥ បន្ទប់មួយអាគារស្មើនឹងពីរជាន់ ១០ បន្ទប់ និង ១ អាគារទៀតស្មើនឹង ០៥ បន្ទប់សំរាប់ឆ្នាំទី ៣
- សាលាអនុវិទ្យាល័យសម្តេច ជា ស៊ីមស្ថិតនៅភូមិ ៣ សាងសង់ ១ អគារពីរជាន់ស្មើនឹង ១០ បន្ទប់សំរាប់ឆ្នាំទី ៣។
- សាលាវិទ្យាល័យកោះកុងស្ថិតនៅក្នុងភូមិ ១ សាងសង់សាលាមាន ២ អគារស្មើនឹង ១១ បន្ទប់ សំរាប់ឆ្នាំទី ១។
- សាលាវិទ្យាល័យកោះកុងក្នុងស្ថិតនៅភូមិ ១ សាងសង់សាលាមាន ០ អគារស្មើនឹង ២ បន្ទប់ សំរាប់ឆ្នាំទី ២។
- ជំរុញ និង ផ្សព្វផ្សាយអោយមានការចូលរួមបង្កើននៅផលិតផលតាមរយៈការរៀបចំជាសួនដំណាំនៅក្នុងដីភូមិ ដូចជាសួនបន្លែ និងដំណាំរួមផ្សំរយៈពេលខ្លី និងវែង ដែលជាកត្តាជួយអោយ

ក្នុងភូមិមានសភាពបែតងស្រស់បំព្រង ដោយមានលទ្ធភាពបង្កើនប្រាក់ចំណូលក្នុងគ្រួសារលើសកម្មភាពនេះ ។

- ចំពោះប្រជាជនដែលរស់នៅលើដីសាធារណៈរបស់រដ្ឋ (ដីមាត់ព្រែក) បច្ចុប្បន្នអ្នកដែលរស់នៅចាស់មានការលំបាកក្នុងការផ្លាស់ប្តូរ ហើយជាបណ្តើរៗ សង្កាត់ និងព្យាយាមធ្វើការរៀបចំអោយបានត្រឹមត្រូវ ប៉ុន្តែជាគោលការណ៍សង្កាត់ធ្វើការហាមឃាតដាច់ខាតការសាងសង់លំនៅដ្ឋានថ្មី ។

### ៣.២.៣.៧ ការប្រើប្រាស់ដីក្នុងកិច្ចការពារធនធានធម្មជាតិ និងបរិស្ថាន

- ការប្រើប្រាស់ដីព្រៃការពារ(ដីសាធារណៈរដ្ឋ) គឺត្រូវទាមទាអោយការថែរក្សាបានគង់វង្សដូច្នេះសង្កាត់មានគោលបំណងធ្វើការរៀបចំនូវផែនការក្នុងការការពារថែរក្សាអភិរក្ស និង អភិវឌ្ឍន៍ទៅលើធនធានព្រៃឈើទាំងនោះ ដើម្បីផ្តល់នៅផលប្រយោជន៍តាមរយៈបង្កើនប្រាក់ចំណូលសំរាប់ប្រជាជនតាមរយៈការប្រើប្រាស់ធនធានព្រៃ ឈើប្រកបដោយនិរន្តភាព ។

នៅក្នុងការប្រែប្រួលដីព្រៃការពារគឺជាអាទិភាពដោយសារដីប្រភេទនោះជាព្រៃរិចរិលដែលស្ថិតក្នុងព្រៃការពារ ដូច្នេះជាគោលការណ៍ត្រូវការពារថែរក្សាទុកអោយព្រៃការពារដុះឡើងវិញ ដើម្បីធានាធនធានព្រៃឈើក្នុងតំបន់ ។

- នៅក្នុងដំណើរការនៃការការពារធនធានធម្មជាតិ និងបរិស្ថាននៅក្នុងសង្កាត់ស្ទាច់មានជ័យត្រូវបានអនុវត្ត និងកំណត់ទៅតាមក្របខណ្ឌនៃការទទួលខុសត្រូវលើការគ្រប់គ្រងរបស់ស្ថាប័ននីមួយៗ និងតំបន់អភិរក្សព្រៃឈើ ។

### បញ្ញត្តិ និងគោលការណ៍នៃការប្រើប្រាស់ធនធាន

នៅក្នុងក្របខណ្ឌនៃការគ្រប់គ្រង និងប្រើប្រាស់ធនធានត្រូវបានរៀបចំគ្រប់គ្រង និងប្រើប្រាស់ទៅលើព្រៃការពារដែលក្នុងនោះត្រូវបានបែងចែក :

- កំណត់ការដកយលផលអនុផលព្រៃឈើត្រូវបានដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រង
- ហាមការចាប់សត្វដែលច្បាប់ព្រៃឈើបានកំណត់
- ហាមកាប់អុសព្រៃការពារធ្វើអាជីវកម្ម
- ហាមការកាប់រានដីព្រៃការពារ
